# ក

# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៦-៦-២០០៣ -ព្រះរាជក្រឹត្យនស/រកត/០៦០៣/១៩១ស្តីពីការតែងតាំងជាប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ -តែងតាំងជាសមាជិក នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា ២១៨៧

០៩-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩៤ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ជូនមន្ត្រីជាន់ខ្ពស់ចំនួន ១៧៥ រូប ២១៨៩

០៩-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩៥ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូន ឯកឧត្តម លោកជំទាវ ជាចៅក្រម ចំនួន ០៨ រូប ដែលមានឋានៈស្មើសមាជិករាជរដ្ឋាភិបាល និង អនុរដ្ឋលេខាធិការ ២១៩៦

០៩-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីវ ជីនមូ** (LIU CHIN MU) ជនជាតិតៃវ៉ាន់ សញ្ជាតិ សឹង្ហបុរី មានទីកន្លែងកំណើតក្រុងតៃប៉ិ ប្រទេសចិន ២១៩៨

១១-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩៨ ស្តីពីការតែងតាំងឯកឧត្តម **ហាក់ ម៉ុនធឿន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ២១៩៩

១៦-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/២០០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក **ឌឺកែស្ទែរ ហ្សង់អ៊ីវ** (DEKEISTER Jean-Yves) សញ្ជាតិដើមបារាំង កើតនៅអេសកែលបិច នៃសាធារណរដ្ឋបារាំង ២២០០

១៦-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/២០១ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក **ឈិន ជីស៊ាង**(CHEN CHIH-HSIANG) សញ្ជាតិដើមចិន កើតនៅប្រទេសចិន ២២០១

១៦-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/២០២ ស្តីពីការតែងតាំង ឯកឧត្តម **ឃុន ជិនកេន** ជា **អគ្គលេខាធិការរងរាជរដ្ឋាភិបាល** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២២០២


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១៧-៦-២០០៣ -អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ២២០៣

១៩-៦-២០០៣ -អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់ដើម្បីដឹកនាំសំរបសំរួល និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ពតិមានវិទ្យា ២២០៦

# ខ


| | | |
|---|---|---|
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យកម្ពុជា | ២២០៨ |
| ២៣-៦-២០០៣ | -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណៈ រដ្ឋបាល | ២២១២ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៤៧ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន | ២២២៧ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៤៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២២៨ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៣០ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២៣១ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២៣២ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៣៣ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៣៤ |
| ១៦-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៣៦ |
| ១៧-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ | ២២៣៨ |
| ១៧-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២២៣៩ |
| ១៧-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២៤០ |
| ១៧-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤១ |
| ១៧-៦-២០០៣ | -អនុក្រឹត្យលេខ ៥៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤២ |
| ១៩-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤៣ |
| ១៩-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២៤៤ |
| ១៩-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤៥ |
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤៧ |
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៤៨ |
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២២៤៩ |
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៥២ |
| ២០-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២៥៣ |
| | *(អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត នឹងចុះផ្សាយនៅលេខបន្ទាប់ ពេលបានទទួល)* | |
| ២៣-៦-២០០៣ | -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៥៤ |
| ២៣-៦-២០០៣ | -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៥៥ |
| ២៣-៦-២០០៣ | -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២២៥៧ |
| ២៣-៦-២០០៣ | -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២២៥៨ |

# ក


២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៦០

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៦១

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៦៥

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៦៦

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៦៧

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧០

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧២

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៣

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៤

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៥

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៦

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៧

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៨

២៣-៦-២០០៣ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៧៩


## ២-សេចក្តីសំរេច


១៦-៦-២០០៣ -សេចក្តីសំរេចលេខ ៤៨ សសរ ស្តីពីការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តក្រចេះ ២២៩៣

១៧-៦-២០០៣ -សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការផ្ទេរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ៍វិទ្យុអេហ្វ អឹមជាតិកម្ពុជា ៩៦ មេហ្គាហឺត ២២៩៦

២០-៦-២០០៣ -សេចក្តីសំរេចលេខ ៥០ សសរ ស្តីពីការកែសម្រួលសមាសភាពការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅ ក្រុងព្រះសីហនុ ២២៩៧


## ៣-សារាចរណែនាំ


១៩-៦-២០០៣ -សារាចរណែនាំលេខ ០៩ សរណន សំរាប់អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំង ព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ ២២៩៩


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រី


១៨-៦-២០០៣ -សេចក្តីសំរេចលេខ ២២ សសរ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៣០២


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១៩-៦-២០០៣ -ប្រកាសលេខ ៤៨៧ ឧថ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់នាយកដ្ឋានកម្មសិទ្ធឧស្សាហកម្ម ២៣០៣

# ឃ

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


២០-៦-២០០៣ -ប្រកាសលេខ ៥៣២ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " ស្រែពោធិ៍ " ទៅជាវិទ្យាល័យ"ហ៊ុន សែនស្ទឹងត្រែង"ស្ថិតនៅក្នុងឃុំស្រះឫស្សី ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ២៣១២

២៣-៦-២០០៣ -ប្រកាសលេខ ៥៣៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ទីពោ ស្ថិតនៅក្នុងឃុំ ទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ២៣១៣

២៣-៦-២០០៣ -ប្រកាសលេខ ៥៣៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រះធម្មស្រះ ស្ថិតនៅក្នុងឃុំ ភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ២៣១៤

២៣-៦-២០០៣ -ប្រកាសលេខ ៥៣៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ថ្មស ស្ថិតនៅក្នុងឃុំ ថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង ២៣១៥

២៣-៦-២០០៣ -ប្រកាសលេខ ៥៣៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ព្រះក្រសាំង ស្ថិតនៅក្នុងឃុំ សានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ២៣១៦

២៣-៦-២០០៣ -ប្រកាសលេខ ៥៣៩ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " ជា ស៊ីម រក្សជ័យ " ទៅជាវិទ្យាល័យ " ជា ស៊ីម រក្សជ័យ " ស្ថិតនៅក្នុងឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ២៣១៧

២៣-៦-២០០៣ -ប្រកាសលេខ ៥៤០ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ " សេរីភាព " ទៅជាអនុវិទ្យាល័យ " ហ៊ុន សែន សេរីភាព " ស្ថិតនៅក្នុងឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ២៣១៨

២៣-៦-២០០៣ -ប្រកាសលេខ ៥៤១ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ " សំពៅពូន " ទៅជាអនុវិទ្យាល័យ " ហ៊ុន សែន សំពៅពូន " ស្ថិតនៅក្នុងឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ២៣១៩

២៣-៦-២០០៣ -ប្រកាសលេខ ៥៤២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ កោះស្រឡៅ ស្ថិតនៅក្នុងឃុំ កោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ២៣២០

២៣-៦-២០០៣ -ប្រកាសលេខ ៥៤៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ បឹងព្រាវ ស្ថិតនៅក្នុងឃុំ បឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ២៣២១

២៣-៦-២០០៣ -ប្រកាសលេខ ៥៤៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ស្ទឹងឆាយ ស្ថិតនៅក្នុងឃុំ ស្ទឹងឆាយ ស្រុកកំពង់សិលា ខេត្តកោះកុង ២៣២២

២៣-៦-២០០៣ -ប្រកាសលេខ ៥៤៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ប៉ាក់ខ្លង ស្ថិតនៅក្នុងឃុំ ប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ២៣២៣

២៣-៦-២០០៣ -ប្រកាសលេខ ៥៤៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ កោះស្តេច ស្ថិតនៅក្នុងឃុំ កោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ២៣២៤

២៣-៦-២០០៣ -ប្រកាសលេខ ៥៤៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ជា ស៊ីម ស្មាច់មានជ័យ ស្ថិតនៅក្នុងឃុំ ស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ២៣២៥

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/១៩១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងជាប្រធាន និង អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជានូវឥស្សរជនដែលមាននាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **តុល ឡោះ** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា | ប្រធាន |
| ២.ឯកឧត្តម **សុខ អាន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |

**មាត្រា ២** : តែងតាំងជាសមាជិក នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សំរាប់អាណត្តិទី ១ នូវឥស្សរជន ០៥ រូប ដែលមានរាយនាម ដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២.ឯកឧត្តម **ឆាយ គីម** | សមាជិក ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៣.ឯកឧត្តម **យូឃាង ចាវរិន** | សមាជិក ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៤.ឯកឧត្តម **ស៊ិន សារុន** | អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥.ឯកឧត្តម **ស៊ុន ម៉េងស្រ៊ុន** | សាស្ត្រាចារ្យ | សមាជិក |

**មាត្រា ៣** : នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រហស្តលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣*

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្ទជាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៖ស.០៣.០៦.២០៦

លេខ : ១៦៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឡោក សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/១៩៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១:** បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ជូនមន្ត្រីជាន់ខ្ពស់ ចំនួន ១៧៥ រូប ដែលមាន ស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ :-

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

-ឯកឧត្តម **គុល ឡោះ**

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **សុខ អាន**

២-ឯកឧត្តម **ទៀ បាញ់**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម **លី ឡាយស្រេង**

២-ឯកឧត្តម **ឈាវ៉ី តាន់**

៣-ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីរត្ន**

៤-ឯកឧត្តម សួរ ឃុន
៥-ឯកឧត្តម ហូ សិទ្ធី
៦-ឯកឧត្តម ឱម យ៉ិនទៀង
៧-ឯកឧត្តម ប្រាក់ សុខុន
៨-ឯកឧត្តម ខៀវ កាញារិទ្ធ
៩-ឯកឧត្តម ឈោ ប៊ុនស្រ៊ី

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

-ឯកឧត្តម យូ ហុកគ្រី

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម ឃុន ហាំង
២-ឯកឧត្តម ស៊ុយ សែម
៣-សម្តេចព្រះរៀម នរោត្តម បុប្ផាទេវី
៤-ឯកឧត្តម ជា សាវឿន
៥-លោកជំទាវ ម្ជូរ សុខហួរ
៦-ឯកឧត្តម ឃី តាំងលីម
៧-ឯកឧត្តម នាង ស៊ីថុង
៨-ឯកឧត្តម ឈី ធុច
៩-ឯកឧត្តម ស៊ុំ ម៉ានិត
១០-លោកជំទាវ ស៊ិន ស៊ីរី
១១-ឯកឧត្តម អ៊ុត ប្រាំង
១២-ឯកឧត្តម សុខ ចិន្តា
១៣-ឯកឧត្តម ឈៀង យ៉ាន់ណារ៉ា
១៤-ឯកឧត្តម យឹម ឆៃលី
១៥-ឯកឧត្តម ត្រាំ អ៊ីវតឹក
១៦-ឯកឧត្តម អ៊ឹម សិទ្ធី
១៧-ឯកឧត្តម អ៊ិន ទិសាអ៊ុម

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-ឯកឧត្តម កៅ ប៊ុនហុង
២-ឯកឧត្តម ជា សោភ័ណ
៣-ឯកឧត្តម ពេជ្រ ប៊ុនធិន
៤-ឯកឧត្តម ប៊ុក សំអែល
៥-ឯកឧត្តម ខាយ ឃុនហោង

៦-ឯកឧត្តម ហុង ថៃម
៧-ឯកឧត្តម ឆឹង ចំរើន
៨-ឯកឧត្តម អ៊ុក រ៉ាប៊ុន
៩-ឯកឧត្តម គង់ វិបុល
១០-ឯកឧត្តម អ៊ុំ ដារ៉ាវុធ
១១-ឯកឧត្តម ញ៉ោប ប៊ុនឃីន
១២-ឯកឧត្តម ឡាយ ព្រហស្ត
១៣-ឯកឧត្តម សុក ស៊ីផាន់ណា
១៤-ឯកឧត្តម ខែក រ៉ាវី
១៥-ឯកឧត្តម ប៊ុក ថន
១៦-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ធីណារ៉ា សិរីវុឌ្ឍ
១៧-ឯកឧត្តម ផាន់ គិន
១៨-ឯកឧត្តម ឡាំ តូអាន
១៩-ឯកឧត្តម ឈុន អឿម
២០-លោកជំទាវ អ៊ុង កន្ថាផាវី
២១-លោកជំទាវ យូ អយ
២២-ឯកឧត្តម ស៊ុយ នូ
២៣-ឯកឧត្តម អង្គវង្ស វឌ្ឍនា
២៤-ឯកឧត្តម អ៊ុំ គីហ៊ាង
២៥-ឯកឧត្តម ទៅ ពិន
២៦-ឯកឧត្តម ហ៊ុយ កន្ធុលវ៉ា
២៧-ឯកឧត្តម វើង សាខុន

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-ឯកឧត្តម ប៊ុន អ៊ុយ
២-ឯកឧត្តម សេង លឹមនៅ
៣-ឯកឧត្តម ម្យាស់ ឈាស់
៤-ឯកឧត្តម ធីន សូសំភ្ញ
៥-ឯកឧត្តម លី អ៊ាងឡាក់
៦-ឯកឧត្តម ស៊ិន សារុន
៧-ឯកឧត្តម ឆឹយ រឿន
៨-ឯកឧត្តម ទើន ឬរី
៩-ឯកឧត្តម ផាន់ ខូន

១០-ឯកឧត្តម ឡាយ អ៊ីពិសិដ្ឋ
១១-ឯកឧត្តម ជុំ សម្ប៉ុន
១២-ឯកឧត្តម អ៊ូ គីមឡឿន
១៣-ឯកឧត្តម អ៊ុន ចាន់ថា
១៤-ឯកឧត្តម លី ឃីម៉ុន
១៥-ឯកឧត្តម ប្រាក់ ហាម
១៦-ឯកឧត្តម ភង ណៃសម
១៧-ឯកឧត្តម យ៉ើរ សម្បត្តិ
១៨-ឯកឧត្តម ឌី ហុក
១៩-ឯកឧត្តម ឌី ចន
២០-ឯកឧត្តម សៀង ឡាប្រេស្ស
២១-ឯកឧត្តម ឡុង មិសាលោ
២២-ឯកឧត្តម ខុង សំនួន
២៣-ឯកឧត្តម ប្រ៉ែស ម៉ាណូឡា
២៤-លោកជំទាវ ស៊ុន សាគៀន
២៥-ឯកឧត្តម ម៉ុន សំ
២៦-ឯកឧត្តម ទី តាយី
២៧-ឯកឧត្តម ញូណ ឡៀង
២៨-ឯកឧត្តម សូរ ទិចធំ
២៩-ឯកឧត្តម ភូច វណ្ណៈ
៣០-ឯកឧត្តម អ៊ី ឈន់
៣១-ឯកឧត្តម ថាច់ ផែន
៣២-ឯកឧត្តម អូន ចំនួសីយ៉ាវុឌ្ឍ
៣៣-ឯកឧត្តម ពៅ យ៉ាដា
៣៤-ឯកឧត្តម ជន សាមួន
៣៥-ឯកឧត្តម ហ៊ុល លីម
៣៦-ឯកឧត្តម ខ្លូត រ៉ាន់អ៊ី
៣៧-ឯកឧត្តម ញ៉ឹក ច្រឹង
៣៨-ឯកឧត្តម តោគ សុវណ្ណារិទ្ធ
៣៩-ឯកឧត្តម គង ចន្ទ
៤០-ឯកឧត្តម អ៊ុក ចាយ
៤១-ឯកឧត្តម សារ៉ាក់ ខាន់

៤២-ឯកឧត្តម ម៉ែន ហាន
៤៣-ឯកឧត្តម កៅ ខុនដាវ៉ែត
៤៤-ឯកឧត្តម ឡិត ប៊ុច
៤៥-ឯកឧត្តម កែវ សុខណៃ
៤៦-ឯកឧត្តម ភីម ស៊ីថន
៤៧-ឯកឧត្តម ឈឹម ណារិទ្ធ
៤៨-ឯកឧត្តម ស៊ឹម គុកហេង
៤៩-ឯកឧត្តម ប៊ុន សុខ
៥០-ឯកឧត្តម ជ័យ ចាប
៥១-ឯកឧត្តម ហែម សំភុល
៥២-ឯកឧត្តម ប៊ូ ជុំសេរី
៥៣-ឯកឧត្តម នូ មុត
៥៤-ឯកឧត្តម ឃឹម សារិទ្ធ
៥៥-ឯកឧត្តម ជុច គៀន
៥៦-ឯកឧត្តម អ៊ុក សុជាតិ
៥៧-ឯកឧត្តម មីសែល ត្រាណេ
៥៨-ឯកឧត្តម គីម សុផាត
៥៩-ឯកឧត្តម ពេជ្រ ឆុំក្រមិល
៦០-ឯកឧត្តម ធីក គ្រៀនឧត្តា
៦១-ឯកឧត្តម ប្រាជ្ញ ស៊ុន
៦២-ឯកឧត្តម អៀម រ៉ា
៦៣-ឯកឧត្តម ធីម ម៉ានី
៦៤-ឯកឧត្តម រ័ត្ន សណ្ដាប់
៦៥-ឯកឧត្តម ចី ចំរុងផល
៦៦-ឯកឧត្តម សួស គង់
៦៧-ឯកឧត្តម ជី សួណា
៦៨-ឯកឧត្តម ឡេង គឹកសេង
៦៩-ឯកឧត្តម យី យ៉ូន
៧០-ឯកឧត្តម សយ ស៊ីផុន
៧១-ឯកឧត្តម វង សុគ្រ
៧២-ឯកឧត្តម យូ បុណ្យណា
៧៣-ឯកឧត្តម ឡា ណារ៉ាត

៧៤-ឯកឧត្តម ឡុង ម៉ាន់ហាន

៧៥-ឯកឧត្តម រស់ សម៉យ

៧៦-ឯកឧត្តម កួយ គីមស៊ា

៧៧-ឯកឧត្តម ម៉ា សុផាន់ណា

៧៨-ឯកឧត្តម ជោក ណារិន

៧៩-ឯកឧត្តម ហ្សាការីយ៉ា អាដាម

៨០-ឯកឧត្តម អ៊ីស្មាឯល ឧស្មាន

៨១-ឯកឧត្តម គ្រួច សារី

៨២-ឯកឧត្តម សៅ ម៉ីន

៨៣-លោកជំទាវ សាន អារុន

៨៤-ឯកឧត្តម សោម ចំនួរ៉ើម

៨៥-លោកជំទាវ យីម ចំរើន

៨៦-លោកជំទាវ អ៊ុំ ចន្ថា

៨៧-លោកជំទាវ នួច ស៊ីរដ្ឋា

៨៨-ឯកឧត្តម អ៊ុក ចាន់

៨៩-ឯកឧត្តម កែម ថន

៩០-ឯកឧត្តម សំ សុខ

៩១-ឯកឧត្តម សួន ហោខ

៩២-ឯកឧត្តម គាន់ ស៊ិនតូ

៩៣-ឯកឧត្តម អ៊ិន នាង

៩៤-ឯកឧត្តម អ៊ុំ ជន

៩៥-ឯកឧត្តម ប៉ុក ម៉ាន់នី

៩៦-ឯកឧត្តម សុដ្ឋ សុធន្ន

៩៧-ឯកឧត្តម អ៊ុំ ប៊ុនធឿន

៩៨-ឯកឧត្តម ម៉ឹម សុផាណា

៩៩-ឯកឧត្តម រំឌួ សារិន

១០០-ឯកឧត្តម ព្រហ្ម សិទ្ធត្រា

១០១-ឯកឧត្តម កែម ខេមរា

១០២-ឯកឧត្តម កើត សារ៉េត

១០៣-ឯកឧត្តម ផង់ សារ៉េត

១០៤-ឯកឧត្តម សំ សារិត

១០៥-ឯកឧត្តម ឆុំ ប៊ុនធឿន

១០៦-ឯកឧត្តម រស្មី ហ៊ុនលី
១០៧-ឯកឧត្តម ម៉ែន គួន
១០៨-ឯកឧត្តម អៀម សារ៉ុ
១០៩-ឯកឧត្តម មួង សៅខន
១១០-ឯកឧត្តម ជុំ អៀក
១១១-ឯកឧត្តម តាន់ ឧត្ដា
១១២-ឯកឧត្តម កែវ សាផល
១១៣-ឯកឧត្តម ឆា សុផ្លា
១១៤-ឯកឧត្តម ម៉ៅ ហាវណ្ណាល់
១១៥-ឯកឧត្តម ម៉ុន ហ៊ាន
១១៦-ឯកឧត្តម លី ចាណា
១១៧-ឯកឧត្តម ណី លន់

៥-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ អស្សឫទ្ធិ :
-ឯកឧត្តម ស្វាយ ស៊ីថា

**មាត្រា២** : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។
**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

នរកត.០៣:០៦.២០៥ លេខ: ៦៧២ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

នស / រកត / ០៦០៣ / ១៩៥

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ : ០៩ ន.ស. ៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូល ស្នើសុំរបស់សម័យប្រជុំថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៣ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា ១ .-**

បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូន ឯកឧត្តម លោកជំទាវ ជាចៅក្រម ចំនួន ០៨ រូប ដែលមានឋានៈស្មើសមាជិករាជរដ្ឋាភិបាល និង អនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម :

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ " **ធិបឌិន្ទ** "

១- ឯកឧត្តម **អ៊ុក វ៉ិធុន** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល

២- លោកជំទាវ **លី ឌួចឡេង** ប្រធានសាលាឧទ្ធរណ៍

៣- ឯកឧត្តម **ហង់ រ៉ូ វ៉ាវេកន** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍

៤- ឯកឧត្តម **ឡៀល មួន** សមាជិក និងជា លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

៥- ឯកឧត្តម **នី វណ្ណាន** អនុប្រធានសាលាឧទ្ធរណ៍ និងជា សមាជិក នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

ខ. គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ " សេនា "

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** អនុប្រធានតុលាការកំពូល

២- ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមតុលាការកំពូល

គ. គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ " អស្សឫទ្ធិ "

១- ឯកឧត្តម **គង់ ស្រ៊ុម** អគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍

**មាត្រា ២ .-**

ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ១៦៤ ច.ល

៣ស.០៣.០៦.២០៦

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/១៩៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/ រកម / ១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ លោក **លីវ ជីនមូ** ( LIU CHIN MU ) ជនជាតិតៃវ៉ាន់ សញ្ជាតិ សឹង្ហបូរី កើតនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៣២ មានទីកន្លែងកំណើតក្រុងតៃប៉ិ ប្រទេសចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ៦៧៣ ច.ល

៣៩៧.០៣.០៦.២០០៣ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស / រកត / ០៦០៣/១៩៨

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តម **ហាក់ ម៉ិនឆឿន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

លេខ : ១៦៦ ច.ល **ហត្ថលេខា និងព្រះរាជលញ្ឆករ**

៣៧ល.០៣.០៦.៦០៩ ដើម្បីចម្លងចែក **ជា ស៊ីម**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/២០០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក ឌឺកែស្ទែរ ហ្សង់អ៊ីវ (DEKEISTER Jean-Yves) សញ្ជាតិដើមបារាំង កើតថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៦៤ នៅអេសកែលបិច នៃសាធារណរដ្ឋបារាំង ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣*

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ១៦៧ ច.ល

៣៩ល-០៣.០៦.២១១ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**គ្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/២០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ជីស៊ាង** (CHEN CHIH-HSIANG) សញ្ជាតិដើមចិន កើតថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៦០ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣*

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ១៦៨ ច.ល

ដើម្បីចម្លងចែក

៣រស-០៣-០៦-២០១

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ប្រាក់ សុខុន**

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦០៣/ ២០៤

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរ័ត្ន

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៩ ចុះថ្ងៃទី ២៤ខែមករាឆ្នាំ១៩៩៦ដែល ប្រកាស អោយប្រើច្បាប់ ស្តីពីការបង្កើត ទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំង ឯកឧត្តម **ឃុន ជិនកេន** ជា **អគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈ ស្មើ អនុរដ្ឋលេខាធិការ** ។

**មាត្រា២.-** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ ទុកជានិរាករណ៍ ។

**មាត្រា៣.-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ចករ**

**ជា ស៊ីម**

លេខ : ១៦៩ច.ល

៣រល-០៣-០៦-២១៣ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ប្រាក់ សុខុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ម៉ៃ ឃើយូ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "**វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី**" "SITC INTERNATIONAL INSTITUTE" ហៅកាត់ជាភាសាខ្មែរ "វ.អ.អ.អ.ធ.ស"

និង ហៅជាភាសាអង់គ្លេស "S.I.I. "។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោលស្ថិតនៅ អាគារលេខ ៣១៥ ផ្លូវ ហ្សាលដឺហ្គូល សង្កាត់ អូរឫស្សីទី ២ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី ធ្វើការបណ្តុះបណ្តាលក៏រិតបរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ក្រេឌីត ជាមធ្យម និងថ្នាក់ម៉ាស្ទ័រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៥៦ ក្រេឌីត ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី មានមហាវិទ្យាល័យ :

១- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម :

- ថ្នាក់បរិញ្ញាប័ត្រ មានឯកទេស គណនេយ្យ គ្រប់គ្រង ពាណិជ្ជកម្មអន្តរជាតិ ទីផ្សារ ហិរញ្ញវត្ថុនិង ធនាគារ និង សណ្ឋាគារនិងទេសចរណ៍ ។
- ថ្នាក់ម៉ាស្ទ័រគ្រប់គ្រងពាណិជ្ជកម្ម មានឯកទេស គ្រប់គ្រងហិរញ្ញវត្ថុនិងធនាគារ និង គ្រប់គ្រង ។

២- មហាវិទ្យាល័យភាសាអង់គ្លេស :

- ថ្នាក់បរិញ្ញាប័ត្រ មានឯកទេស ការអប់រំភាសាអង់គ្លេស ។

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ក៏រិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេចលើគោលនយោបាយ ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្រៈ បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺសញ្ញាប័ត្រដែលមានតំលៃស្មើ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់ អំពីការជ្រើសរើសនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** នាយក វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានភារកិច្ច :

- ទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និងសេចក្តីណែនាំ របស់ក្រសួងអប់រំ យុវជននិងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។

- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់ កម្មវិធីសិក្សា របស់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្របរិញ្ញា ឬ សញ្ញាប័ត្រម៉ាស្ទ័រ តាមឯកទេស និង តាមកំរិត ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយ វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាព-ពាក់ព័ន្ធ និង វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិតាម អនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"<u>ដើម្បីមុខការ</u>"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារជាន់ខ្ពស់ដើម្បីដឹកនាំសំរបសំរួល និង រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា។
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល។

## សំរេច

**មាត្រា ១ :** បង្កើតក្រុមការងារជាន់ខ្ពស់មួយ ដើម្បីដឹកនាំសំរបសំរួលការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំរាប់អភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា (ICT) ។

ក្រុមការងារជាន់ខ្ពស់ មានភារកិច្ចពិភាក្សាពិគ្រោះយោបល់ និងសំរបសំរួលជាមួយស្ថាប័នផ្តល់ជំនួយ ស្ថានទូតនានាប្រចាំនៅកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអប់រំ ដើម្បីរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រជាតិ ឯកសារជាតិជាផ្លូវការស្តីពីការប្រើប្រាស់ ICT ដូចជា :

- ពិនិត្យ ខ្លឹមសារសេចក្តីព្រាងឯកសាររបស់ក្រុមការងារបច្ចេកទេសនិមួយៗ ។
- កំណត់ចំនួនអ្នកស្រាវជ្រាវជាតិដើម្បីធ្វើសេចក្តីព្រាងឯកសារសំរាប់សិក្សាលើវិស័យ ICT របស់ក្រុមការងារបច្ចេកទេសនិមួយៗ ។
- ផ្តល់ការណែនាំជារួមដល់ការស្រាវជ្រាវរបស់ក្រុមការងារបច្ចេកទេស ដើម្បីរៀបចំឯកសារដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់ជាតិ ។
- ធានាថា កិច្ចប្រជុំកំពូលស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រ និងកិច្ចពិគ្រោះយោបល់ជាតិស្របតាមកម្មវត្ថុនៃគំរោង ។
- ពិនិត្យលើការរៀបចំឯកសារចុងក្រោយស្តីពីគោលនយោបាយ ។
- ជួយ និងផ្តល់ការណែនាំអំពីវិធីបញ្ចូលឯកសារចុងក្រោយស្តីពីគោលនយោបាយទៅក្នុងអនុក្រឹត្យ ស្របតាមនីតិវិធីចាំបាច់របស់ជាតិ ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា ។
-ធានាថា សន្និសីទជាតិមួយត្រូវបានរៀបចំឡើងដើម្បីលាតត្រដាងពត៌មានអំពីឯកសារចុងក្រោយស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រតាមបណ្តាញអេឡិចត្រូនិច ។

**មាត្រា ២ :** សមាសភាពក្រុមការងារជាន់ខ្ពស់រួមមាន :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម | លោកជំទាវរដ្ឋមន្ត្រី | ប្រូរដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ | សមាជិក |
| ៣- ឯកឧត្តម | **សឺន សំណាង** | ប្រធានរាជបណ្ឌិតសភាកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម | **ពិត ចំណាន** | សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៥- ឯកឧត្តម | **ភូ លីវុឌ្ឍ** | អគ្គលេខាធិការ NiDA | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ៣ :** សមាជិកអចិន្ត្រៃយ៍មានភារកិច្ចសំរបសំរួលការងារទូទៅរវាងក្រុមការងារជាន់ខ្ពស់ និង ក្រុមការងារបច្ចេកទេសដែលនឹងត្រូវបង្កើតឡើងដោយប្រកាសមួយដាច់ដោយឡែក ។

**មាត្រា ៤ :** ក្នុងករណីចាំបាច់ ប្រធានក្រុមការងារជាន់ខ្ពស់អាចលើកសំណើបំពេញបន្ថែមសមាជិករបស់ខ្លួនតាមតំរូវការជាក់ស្តែង ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិកក្រុមការងារជាន់ខ្ពស់ ដូចមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យឱ្យបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ[illegible] ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

ចំលងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័ន*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោកបណ្ឌិត កៅ គឹមហួន ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១.-**

ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **"សាកលវិទ្យាល័យកម្ពុជា"** (The University of Cambodia) ហៅកាត់ជាភាសាខ្មែរ "ស.ក " និងហៅជា ភាសាអង់គ្លេស "UC" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោលស្ថិតនៅ អាគារលេខ ១៤៥ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ២.-**

សាកលវិទ្យាល័យកម្ពុជា ធ្វើការបណ្តុះបណ្តាល :

- ថ្នាក់ បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ។
- ថ្នាក់ ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ។
- ថ្នាក់ បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ឆ្នាំ ។

សាកលវិទ្យាល័យកម្ពុជា ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

សាកលវិទ្យាល័យកម្ពុជា មានមហាវិទ្យាល័យចំនួន ០៥ វិទ្យាស្ថាន ០២ និង មជ្ឈមណ្ឌល ០២ :

១. មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និង ភាសាវិទ្យា
២. មហាវិទ្យាល័យ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
៣. មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
៤. មហាវិទ្យាល័យ រដ្ឋបាលសាធារណៈ និង ពាណិជ្ជសាស្ត្រ
៥. មហាវិទ្យាល័យ អប់រំ
៦. វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៧. វិទ្យាស្ថានសិក្សាស្រាវជ្រាវជាន់ខ្ពស់
៨. មជ្ឈមណ្ឌលសិក្សាអាស៊ាន និង អាស៊ីខាងកើត
៩. មជ្ឈមណ្ឌលសិក្សាអន្តរជាតិ

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ កំរិត ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

### មាត្រា ៤.-

សាកលវិទ្យាល័យកម្ពុជា ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និង សាកលវិទ្យាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ សាកលវិទ្យាល័យមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និងមានក្រុមប្រឹក្សាសិក្សាមួយមានតួនាទីពិនិត្យ និងផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

### មាត្រា ៥.-

លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់ បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុតបានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់ បរិញ្ញាប័ត្រ : បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។
- ថ្នាក់ ម៉ាស្ទ័រ : បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ បណ្ឌិត : បេក្ខជនត្រូវមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។

សាកលវិទ្យាល័យកម្ពុជា ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែល កំណត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

### មាត្រា ៦.-

សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យកម្ពុជា មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន និង ជ្រើសរើសសាស្រ្តាចារ្យមកបង្រៀន និងបុគ្គលិកមកបំរើការងារ។
- គ្រប់គ្រងឱ្យបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្តតាម សារាចរ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាឱ្យបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា ឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៧.-**

និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យកម្ពុជា និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យនេះបំពេញ និង អនុវត្ត បានតាមគោលការណ៍កំណត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យកម្ពុជា មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩.-**

អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *សាលាក្រុងភ្នំពេញ*

*" ដើម្បីជ្រាប "*

- *ដូចមាត្រា ៨ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស-រកម-០១៩៦/០២ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦.១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១២៩៧/៥១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ-បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈសរសេរកាត់ថា ស.ភ.វ.ស. ត្រូវបានសម្រេចឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២.-**

ស.ភ.វ.ស. ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ

ស.ភ.វ.ស. មានទីស្នាក់ការកណ្តាល អាសយដ្ឋានលេខ ៥ វិថីសម្តេចអ៊ុក សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ។ ការផ្លាស់ប្តូរ អាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ ស.ភ.វ.ស. ។

**មាត្រា ៣.-**

ស.ភ.វ.ស. មានភារកិច្ចជាអាទិ៍ដូចតទៅ :

- បណ្តុះបណ្តាលអ្នកឯកទេស អ្នកបច្ចេកទេស វប្បធម៌ និងវិចិត្រសិល្បៈ ថ្នាក់ឧត្តម និងក្រោយឧត្តម គ្រប់កំរិតតាមស្តង់ដាជាតិ និង អន្តរជាតិ និងធ្វើវិក្រឹតការ សុក្រឹតការ អ្នកបច្ចេកទេស បង្កើនទាំងបរិមាណ និងគុណភាព ស្របតាមសំណូមពរនៃសេចក្តីត្រូវការទីផ្សារក្នុងប្រទេស និងក្រៅប្រទេស តាមប្រព័ន្ធសាកលវិទ្យាល័យតាមរយៈ ការអប់រំ ការបង្រៀន ការរៀន និងការបណ្តុះបណ្តាលមុខរបរវិជ្ជាជីវៈវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងការបណ្តុះបណ្តាលបន្ត ដែលផ្តល់ឯកទេសជំនាញប្រកបដោយគុណភាព វិញ្ញាបនបត្រ និងសញ្ញាបត្រ ព្រមទាំងរៀបចំ និងបើក សិក្ខាសាលា សន្និសីទផ្សេងៗតាមសំណូមពរសង្គម

- បង្កើនសមត្ថភាព មុខជំនាញ បច្ចេកទេស ដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងវិទ្យាល័យវិចិត្រសិល្បៈ សិល្បៈអាជីព និងមហាជន ទូទាំងប្រទេស

- រៀបចំកម្មវិធីសិក្សា និងសូមការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ដោយឡែកកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានការទទួលស្គាល់បន្ថែមពីគណកម្មាធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

-ផ្តល់ និងរួមផ្តល់ ជាមួយគ្រឹះស្ថាន បណ្តុះបណ្តាល ដទៃទៀត នូវសញ្ញាបត្រកម្រិតជាតិ

- រៀបចំ ស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប កំណាយបុរាណវិទ្យា និងការងារផលិតកម្ម ក្នុងវិស័យ វប្បធម៌ និង វិចិត្រសិល្បៈ

- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារ បច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាខ្មែរ និង ភាសាបរទេស ឱ្យបានសមស្របសំរាប់ប្រើប្រាស់ និងសំរាប់ផ្សព្វផ្សាយទូទៅ

- រៀបចំ និងដំណើរការការងារប្រឡងទេពកោសល្យជំនាញសិល្បៈជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ វាយតំលៃការសិក្សាផ្ទៃក្នុង ឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយ តម្លាភាព

- កសាងផែនការមូលដ្ឋាន សម្ភារៈសំរាប់ ស.ភ.វ.ស.

- ដើរតួជាសេនាធិការឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក្នុងការកសាងធនធានមនុស្សលើវិស័យ វប្បធម៌ និងវិចិត្រសិល្បៈ

- គ្រប់គ្រងមន្ត្រីរាជការ កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ ស.ភ.វ.ស.

- ទាក់ទងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុង គោលបំណងធ្វើឱ្យកាន់តែល្អប្រសើរ នូវការអប់រំសិក្សា ការស្រាវជ្រាវ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប ។

## ជំពូកទី ២
## រដ្ឋបាល និង ការគ្រប់គ្រង

### ផ្នែកទី ១
### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

ស.ភ.វ.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែង ការងារ ក្នុងក្របខ័ណ្ឌ នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា ៥.-**

៥.១ - ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧ រូប ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| - តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| - តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - ឥស្សរជនមានចំណេះដឹង និងបទពិសោធន៍ខាងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាសមាជិកស្វ័យប្រវត្តិ
- តំណាងបុគ្គលិក នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាសមាជិកស្វ័យប្រវត្តិ

៥.២-តំណាងបុគ្គលិក នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិក **ស.ភ.វ.ស.**

៥.៣-ប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំង ដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ស្ថាប័នដែល ខ្លួនតំណាងឱ្យ ។

## មាត្រា៦.-

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើស ក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារ យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ គ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យវប្បធម៌ និងវិចិត្រសិល្បៈ សេដ្ឋកិច្ច អប់រំ ឬ នីតិសាស្ត្រ ដែលមាន សញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មក៏រិតធ្ងន់ពីតុលាការឡើយ ។

## មាត្រា ៧.-

៧.១- ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល

៧.២-ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែល មានបទពិសោធន៍ លើវិស័យបណ្តុះបណ្តាលវប្បធម៌ និង វិចិត្រសិល្បៈ អ្នកគ្រប់គ្រងទីផ្សារវប្បធម៌ និង វិចិត្រសិល្បៈអ្នកគ្រប់គ្រងវប្បធម៌ទេសចរណ៍ និងតំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំរបស់ក្រុម ប្រឹក្សាភិបាល ។ ឥស្សរជនទាំងនេះ មានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

## មាត្រា ៨.-

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់សាកលវិទ្យាល័យ ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ :

- ពិនិត្យ និងសំរេចលើគំរោងផែនការអភិវឌ្ឍន៍នៃ ស. ភ. វ. ស. ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសំរេចលើចំណូល និងចំណាយជាប្រចាំព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ ស. ភ. វ. ស.
- ពិនិត្យ និងសំរេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅដល់អង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍន៍តាមការចាំបាច់

- កំណត់នូវរបបជ្រើសរើស ការតម្លើងឋានៈ ការផ្តល់លាភការ ដល់បុគ្គលិក ស.ភ.ខ.ស. ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះភ្នាក់ងារមុខងារសាធារណៈ

- សម្រេចលើចំនួនបុគ្គលិកក្របខ័ណ្ឌដែលអនុញ្ញាតសំរាប់ ស.ភ.ខ.ស.

- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្ម

- កំណត់បទបញ្ជាផ្ទៃក្នុងនៃ ស.ភ.ខ.ស.

- ធ្វើការវាយតំលៃតាមចន្លោះពេលទៀងទាត់លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ ដោយ ស.ភ.ខ.ស. ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

## មាត្រា ៩.-

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ ក្រុមប្រឹក្សាភិបាល ។

## មាត្រា ១០.-

១០-១- ក្រុមប្រឹក្សាភិបាលនៃ ស.ភ.ខ.ស. ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ ( ពីរភាគបី ) ឡើងទៅ ឬ តាមការស្នើសុំពីសាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើស សមាជិកណាម្នាក់ដែលមានវ័យចំណាស់ជាងគេ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បី ដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការ នៃអង្គប្រជុំ១ ( មួយ ) រូប ដែល មិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះ គ្មានសិទ្ធិបោះឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាលតែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈ ព្រម ទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុម ប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុង អនុក្រឹត្យ នេះយ៉ាងតិច ១០ ( ដប់ ) ថ្ងៃ មុនថ្ងៃប្រជុំ

១០-២- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិក វត្តមានចំនួន លើសពី ៥០ ( ហាសិប ) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូន តំណាងឱ្យមកប្រជុំ ជំនួសខ្លួនបានឡើយ ។ បើសិនសំឡេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះ ប្រជុំម្តងទៀតយ៉ាងយូរ ១៥ ( ដប់ប្រាំ ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តំរូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាន ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព

១០-៣-សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដកល់ទុកនៅទីស្នាក់ការរបស់ ស.ន.ខ.ស. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ពន្ធ័ យ៉ាងយូរ ១០ ( ដប់ ) ថ្ងៃ ក្រោយពេលប្រជុំ

១០-៤- ស.ន.ខ.ស. ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ :

- កំណត់ហេតុនៃការប្រជុំរបស់ ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍របស់សាកលវិទ្យាល័យ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

១០-៥- ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនឱ្យហួសពី ១៥ ( ដប់ប្រាំ ) ថ្ងៃ ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិរបស់សាកលវិទ្យាល័យ

**មាត្រា១១.-**

ស.ន.ខ.ស. ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។ សាកលវិទ្យាធិការនេះមានតួនាទី ជានាយកប្រតិបត្តិ ។

**មាត្រា ១២.-**

១២-១- សាកលវិទ្យាធិការនៃ ស.ន.ខ.ស. មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ ក្រុមប្រឹក្សាភិបាល ។

សាកលវិទ្យាធិការមានភារកិច្ច :

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំង ដាក់ឱ្យដំណើរការនូវនយោបាយដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសំរាប់ ស.ន.ខ.ស. ហើយដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យសំរេច
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរាល់សកម្មភាពផ្សេងទៀត ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច

- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្ណាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ ស. ភ. ច. ស. ក្នុងក៏រិតក្របខណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រមចំពោះបុគ្គលិកទាំងមូលរបស់ ស. ភ. ច. ស.
- សម្រេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដោយ អនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែក សិទ្ធិអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដ៏ទៃទៀត ស្តីពីបញ្ហានេះ

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យ តាមបទបញ្ជាផ្ទៃក្នុង របស់ ស. ភ. ច. ស. និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

១២.២- សាកលវិទ្យាធិការ នៃ ស. ភ. ច. ស. ជាដំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន

១២.៣- សាកលវិទ្យាធិការ នៃ ស. ភ. ច. ស. ត្រូវស្នើទៅក្រុមប្រឹក្សាភិបាលសុំតែងតាំង សាកលវិទ្យាធិការរងមួយរូប ឬ ច្រើនរូប ជាជំនួយការតាមការចាំបាច់ ។

## ផ្នែកទី៣
## បុគ្គលិករបស់ ស.ភ.ច.ស.

**មាត្រា ១៣.-**

១៣.១ - បុគ្គលិកអចិន្ត្រៃយ៍របស់ ស. ភ. ច. ស. រួមមានមន្ត្រីរាជការក្របខ័ណ្ឌ មុខងារសាធារណៈមកពី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬ ជ្រើសរើសតាមសំណើរបស់សាកល វិទ្យាធិការ នៃ ស. ភ. ច. ស. ។ មន្ត្រីទាំងអស់នេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌ ប្រាក់បៀវត្ស និងប្រាក់កំរៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាព ដើមរបស់ខ្លួន

១៣.២ - សាកលវិទ្យាល័យអាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការ និងបុគ្គលិកអណ្តែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ

១៣.៣ - បុគ្គលិក ស. ភ. ច. ស. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជា ស្តីពី បុគ្គលិកសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃ លើកទឹកចិត្ត ចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់ " ស.ភ.ចៈស. "

**មាត្រា ១៤.-**

១៤.១- ស.ភ.ច.ស. ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ :-

ដីជាទីតាំងនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានសមាសភាគផ្ទៃក្នុង ២ (ពីរ) មណ្ឌល ដែលមានឈ្មោះដូចតទៅ :-

- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មណ្ឌលខាងជើង មានផ្ទៃដី ៣៧.៥០០ ម$^{2}$ ស្ថិតនៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មណ្ឌលខាងត្បូង មានផ្ទៃដី ១៧.០១៣ម$^{2}$ ស្ថិតនៅសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

១៤.២- ក្រៅពីអចលនទ្រព្យខាងលើ ស.ភ.ច.ស. ត្រូវបានទទួលនូវចលនទ្រព្យ និងអចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣- អចលនទ្រព្យ និងចលនទ្រព្យទាំងអស់របស់ ស.ភ.ច.ស. មានចែងលំអិតក្នុងបញ្ជីសារពើភណ្ឌ ។

១៤.៤- ស.ភ.ច.ស. អាចទិញ លក់ចលនទ្រព្យ និង ទិញអចលនទ្រព្យចាំបាច់សំរាប់ដំណើរការរបស់ខ្លួន ។

## ផ្នែកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ " ស.ភ.ច.ស. "

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ ស.ភ.ច.ស. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យ លេខ ៨២ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦.-**

១៦.១- សាកលវិទ្យាធិការ នៃ ស.ភ.ឌ.ស. ជាអាណាប័កដើមខ្សែរបស់សាកលវិទ្យាល័យ ហើយត្រូវមានភារកិច្ច :-

- ពិនិត្យប្រាក់ និង ទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២-អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវ រជ្ជទេយ្យចំណូល ឬ បុរេប្រទានបានដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

**មាត្រា ១៧.-**

១៧.១ - ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាម បទបញ្ជាផ្ទៃក្នុងរបស់ ស.ភ.ឌ.ស. ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យនេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែគ្មានសិទ្ធបោះឆ្នោតឡើយ

១៧.២ ភ្នាក់ងារគណនេយ្យមានភារកិច្ច :

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់សាកលវិទ្យាល័យ
- រក្សាទុកលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ

១៧.៣ ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុកូរីរបស់ខ្លួន ។

**មាត្រា ១៨.-**

១៨.១ ប្រភពធនធានរបស់ ស.ភ.ឌ.ស. រួមមាន :

- ធនធានដំបូងដែលរដ្ឋផ្តល់ ដល់ ស.ភ.ឌ.ស. នៅពេលផ្តើម បង្កើតដំបូង
- ឧបត្ថម្ភកធនសម្រាប់ដំណើរការ និងឧបត្ថម្ភកធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទានដែល ស.ភ.ឌ.ស. បានទទួល
- ប្រាក់ខ្ចីបុលដោយសាកលវិទ្យាល័យផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ ស.ភ.ឌ.ស.

- ផលនៃការងារ និងកម្រៃនៃការផ្ដល់សេវាផ្សេងៗដោយ **ស. ភ. ខ. ស.**
- កម្រៃនៃទ្រព្យសម្បត្តិរបស់ **ស. ភ. ខ. ស.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ **ស. ភ. ខ. ស.** ។

១៨.២ ចំណូលនិងចំណាយជាប្រចាំ ព្រមទាំងមូលធនរបស់ **ស. ភ. ខ. ស.** ត្រូវបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ ។ ក្រុមប្រឹក្សាភិបាលរបស់ **ស. ភ. ខ. ស.** ត្រូវចែង អំពីបែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកា ។ សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣ ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្មែរ **ស. ភ. ខ. ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញាក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ។

**មាត្រា ១៩.-**

១៩.១- ការងារគណនេយ្យរបស់ **ស. ភ. ខ. ស.** រួមមាន :-

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគប្រសិនបើជាការចាំបាច់

គណនេយ្យរបស់សាកលវិទ្យាល័យត្រូវ :

១- ស្របតាមវិធានដែលកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២- គោរពតាមប្លង់គណនេយ្យរបស់ **ស.ភ.ខ.ស.**ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណនេយ្យនេះត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.២- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សាកលវិទ្យាល័យត្រូវរៀបចំ ដោយភ្នាក់ងារគណនេយ្យ និងអាណាប័កដើមខ្មែរ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូន ក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ ( បី ) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០.-**

មូលនិធិរបស់ **ស.ភ.ទ.ស.** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិបញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃ " ស.ភ.ទ.ស. "

**មាត្រា ២១.-**

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ **ស. ភ. ទ. ស.** ត្រូវស្ថិតនៅក្រោម នីតិរូបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្ត លើអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី ៧

## លទ្ធកម្មរបស់ " ស.ភ.ទ.ស. "

**មាត្រា ២២.-**

ការសម្រេច ការអនុវត្ត និង ការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ស. ភ. ទ. ស.** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យ លេខ ៦០ អនក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពី លទ្ធកម្ម សាធារណៈ និងបទបញ្ជាដទៃទៀតពាក់ព័ន្ធ នឹងបទបញ្ជានេះ ។

# ជំពូកទី ៣

# អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣.-**

២៣-១-ក្នុងរយៈពេល១៥ ( ដប់ប្រាំ ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ **ស.ភ.ទ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ ( មួយ ) ខែ ចាប់ពីថ្ងៃ ដែលបានទទួលឯកសារ សំរាប់រៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ រដ្ឋមន្ត្រី

4u

អាណាព្យាបាល បច្ចេកទេសមាន ២ ( ពីរ ) ខែ គិតពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូន ដោយសាកលវិទ្យាធិការ ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២- លិខិតយល់ព្រមត្រូវចុះហត្ថលេខា ត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬតំណាង ហើយត្រូវ បានផ្ញើជូនសាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ត្រូវបញ្ជូនពត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ប្រសិនបើរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈធ្វើការជំទាស់លើការអភិវឌ្ឍ ឬ គម្រោងថវិកានេះ ប្រធាន ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍ នៃ ស.ភ.ខ.ស. និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ ( ដប់ពីរ ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤.-**

២៤.១- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចមានយោបល់ជំទាស់លើ ឯកសារដែលត្រូវបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ២៣ ខាងលើមាន : កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរយៈ ពេល ១ ( មួយ ) ខែ សំរាប់លើកឡើង នូវការជំទាស់ទាំងអស់នេះ ។

២៤.២- សាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវ ខ្លឹមសារនៃការជំទាស់របស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់ បំផុតលើការជំទាស់របស់រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាល សម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២៥.-**

២៥.១- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចលុប ឬផ្អាកទុកនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬ សាកលវិទ្យាធិការនៃ ស.ភ.ខ.ស. ក្នុងករណីដែលសេចក្តី សម្រេចនោះ :

- ផ្ទុយនឹងគោលដៅរបស់សាកលវិទ្យាល័យ
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើផ្ទុយ នឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២- ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាស របស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹង ពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់សាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ហើយសាកលវិទ្យាធិការ ត្រូវជូនពត៌មានបន្តទៅ ក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦. -**

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារ ក្នុងសាកលវិទ្យាល័យ ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និង បែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧. -**

២៧.១ - ក្នុងរយៈពេល ១៥ ( ដប់ប្រាំ ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរយៈពេល ១ ( មួយ) ខែ គិតពី ថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេល២ (ពីរ) ខែ គិតពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយសាកលវិទ្យាធិការនៃ ស.ភ.ខ.ស. ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២ - លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ ដំណាង ត្រូវផ្ញើទៅសាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ដោយចំលងជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ សាកលវិទ្យាធិការ នៃ ស.ភ.ខ.ស. ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។ ក្នុងករណីដែល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូច បានកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណី ដែល រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់បំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍

ហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ដែលលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៨.-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការនៃ **ស.ភ.ជ.ស.** ត្រូវដាក់សុំការអនុញ្ញាតិជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមការផ្តល់យោបល់ពី មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន :

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេច ស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសំរាប់ការធានា ឬ លិខិតស្រដៀងគ្នានេះ ។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ **ស.ភ.ជ.ស.** ។ មន្ត្រីនេះមាន ភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងក្រោយលើ **ស.ភ.ជ.ស.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣០**

៣០-១ - ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ **ស.ភ.ជ.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០-២ - ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារ គណនេយ្យកណ្តាល នៃធនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០-៣ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬ ការត្រួតពិនិត្យលើសាកលវិទ្យាល័យ នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ ពាក់ព័ន្ធ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

# ជំពូកទី ៥

# អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៣ . អនុក្រ . តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១** : ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-ឧត្តមសេនីយ៍ត្រី **ហ៊ឹង ឡាង** អត្តលេខ ០០០២១៨ នាយការិយាល័យសេនានុព័ន្ធ និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតុឡាវ បច្ចុប្បន្នជា នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋានយោធសេវា ។

២-វរសេនីយ៍ឯក **តែប សម្បត្តិ** អត្តលេខ ០០១៨៣៥ នាយការិយាល័យប្រតិបត្តិការ នាយកដ្ឋានទាក់ទងអន្តរជាតិ បច្ចុប្បន្នជា នាយការិយាល័យសេនានុព័ន្ធ និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត្តឡាវ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

លេខ: ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៤/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់

**សំរេច**

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនដល់អស់លោក លោកស្រី ជាមន្ត្រីរាជការ ចំនួន ១១រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :

១ : លោក ង៉ូវ ប៊ូរីណា អគ្គនាយករងរដ្ឋបាល ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

២ : លោក អៀង ណារិន ជំនួយការផ្ទាល់ឯកឧត្តម មល់ រឿប ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

៣ : លោក ចៅ សម្បត្តិ ប្រធានការិយាល័យភស្តុភា មន្ទីរពេទ្យ១-៧៩

៤ : លោក រស់ លន់ ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តកណ្តាល

៥ : លោក សុខ អឿន ប្រធានមន្ទីរវប្បធម៌វិចិត្រសិល្បៈខេត្តកណ្តាល

៦ : លោក ខៀវ សំអាត អភិបាលស្រុកល្វាឯម ខេត្តកណ្តាល

៧ : លោក អ៊ូ ស៊ីយុន អភិបាលរងស្រុកល្វាឯម ខេត្តកណ្តាល

៨ : លោក ចិន សេន ជំនួយការឯកឧត្តម ប្រធានក្រុមការងារ

៩ : លោកស្រី សរ សាលីម ប្រធានការិយាល័យកិច្ចការនារី និង អតីតយុទ្ធជន ស្រុកល្វាឯម ខេត្តកណ្ដាល

១០: លោក ហេង ធៀម ប្រធានមន្ទីរស្រុកល្វាឯម ខេត្តកណ្ដាល

១១: លោក តូ សារី នាយកវិទ្យាល័យទឹកឃ្លាំង

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា និងអភិបាលខេត្តកណ្ដាលត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៩ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ដូចជាសាលារៀន ផ្លូវលំ វត្តអារាម នៅតាមបណ្តាស្រុក នៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោកជំទាវ | **ខួត ស៊ីដ្ឋា** | ភរិយា ឯកឧត្តម **ម៉ៅ គិរុណា** | ទឹកប្រាក់ | ១៣.២៥០ ដុល្លារ |
| ២-លោកជំទាវ | **យិន អ៊ុយនី** | ភរិយា ឯកឧត្តម **ឃូ ស៊ុនឡុង** | ទឹកប្រាក់ | ១២.៦៨៣ ដុល្លារ |
| ៣-លោកជំទាវ | **ញ៉ែម សេដ្ឋា** | ភរិយា ឯកឧត្តម **អ៊ិត ច្រាំង** | ទឹកប្រាក់ | ១០.២២៥ ដុល្លារ |
| ៤-លោក | **ចាយ បូរិន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ | ១៩.០០០ ដុល្លារ |
| ៥-លោក | **គង់ លី** | សប្បុរសជន នៅខេត្តកំពង់ចាម | ទឹកប្រាក់ | ១៩.០០០ ដុល្លារ |
| ៦-លោក | **នាង ហ៊ុំ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ | ១០.០០០ ដុល្លារ |
| ៧-ព្រះតេជគុណ | **កែវ សារិន** | ចៅអធិការវត្តបឹងត្រាវ | ទឹកប្រាក់ | ១០.០០០ ដុល្លារ |
| ៨-លោកយាយ | **អ៊ិល ណាន** | | ទឹកប្រាក់ | ១៣.០០០ ដុល្លារ |
| ៩-លោកតា | **ស្រី ឈឿន** | | ទឹកប្រាក់ | ១២.៥០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

139

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនសប្បុរសជន ចំនួន ០៦ រូប ដែលបានបរិច្ចាគកម្លាំងកាយ ចិត្ត និង ធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង និង អភិវឌ្ឍន៍ វិស័យអប់រំ សង្គមកិច្ច និង ព្រះពុទ្ធសាសនា នៅតាមបណ្តាស្រុក នៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ឧកញ៉ា | **ស្រី** | **ខួន** | សប្បុរសជន នៅក្រុងភ្នំពេញ |
| ២-លោកជំទាវ ឧកញ៉ា | **ស្រី** | **ទុន្នី** | សប្បុរសជន នៅក្រុងភ្នំពេញ |
| ៣-ឯកឧត្តម | **ម៉ៅ** | **គិរុណ** | អភិបាលរង ទី២ ខេត្តកំពង់ចាម |
| ៤-ឯកឧត្តម | **យូ** | **ស៊ុនឡុង** | សប្បុរសជន នៅក្រុងភ្នំពេញ |
| ៥-ឯកឧត្តម | **មុត** | **ខៀវ** | សប្បុរសជន នៅក្រុងភ្នំពេញ |
| ៦-ឯកឧត្តម | **អ៊ិត** | **ច្រាំង** | សប្បុរសជន នៅក្រុងភ្នំពេញ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកំពត

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក វរសេនីយ៍ឯក **ម៉ែត ចាន់ណារ៉ា** មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តកំពត ដែលមានស្នាដៃល្អ ក្នុងការដឹកនាំភារកិច្ចការពារសន្តិសុខ សុវត្ថិភាព ជូនប្រទេសជាតិ និងប្រជាពលរដ្ឋ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូន*មូលនិធិ ដុនបូស្កូកម្ពុជា នៃ សហភាពអឺរុប* ដែលបានផ្តល់ ថវិកា ចំនួន ៣០.០០០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់ អគារសិក្សា០១ខ្នង មាន០៦ បន្ទប់ និង បង្គន់អនាម័យ ០៥ បន្ទប់ នៅសាលាបឋមសិក្សា ពញាអង្គរ ឃុំវត្តអង្គខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៧ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យព្រះពុទ្ធសាសនា និង អប់រំ នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

**ក‑មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **អ៊ី** | **គឹមហ៊ាង** | រដ្ឋលេខាធិការក្រសួងធនធានទឹក | ទឹកប្រាក់ ១១.១៣០ ដុល្លារ |
| ២-ឯកឧត្តម | **ជឿន** | **សុវណ្ណថា** | មេបញ្ជាការយោធភូមិភាគ ២ | ទឹកប្រាក់ ១១.៦៦០ ដុល្លារ |
| ៣-ឯកឧត្តម | **ម៉ៅ** | **តិរុណ** | អភិបាលរងទី២ ខេត្តកំពង់ចាម | ទឹកប្រាក់ ១៣.០០០ ដុល្លារ |
| ៤-លោកជំទាវ | **ខ្លូត** | **ស៊ីដ្ឋា** | ភរិយាឯកឧត្តម **ម៉ៅ តិរុណ** | ទឹកប្រាក់ ១១.០០០ ដុល្លារ |
| ៥-លោក | **ហៃ** | **ខួនលី** | អគ្គលេខាធិការរងសាលាខេត្តកំពង់ចាម | ទឹកប្រាក់ ១១.០០០ ដុល្លារ |
| ៦-ឧកញ៉ា | **ម៉ក់** | **គឹមហុង** | ប្រធានអគ្គនាយកចំការកៅស៊ូជុប | ទឹកប្រាក់ ១៨.០០០ ដុល្លារ |
| ៧-ព្រះគ្រូ | **ឈឹម** | **ភយ** | ចៅអធិការ វត្ត ត្រពាំងឫស្សី | ទឹកប្រាក់ ១០.០០០ ដុល្លារ |
| ៨-ព្រះតេជគុណ | **គឹម** | **ឈាង** | ចៅអធិការ វត្ត ឧទុម្ពរ | ទឹកប្រាក់ ១០.០០០ ដុល្លារ |
| ៩-លោក | **គឹម** | **តៅ** | ប្រធានក្រុមហ៊ុនចំការកៅស៊ូតាប៉ាវ | ទឹកប្រាក់ ១០.០០០ ដុល្លារ |

**ខ‑មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ខូច** | **ជូ** | សប្បុរសជននៅក្រុងភ្នំពេញ | ទឹកប្រាក់ ៦.៥០០ ដុល្លារ |
| ២-លោក | **ឡាន់** | **ឆន** | អភិបាលស្រុកត្បូងឃ្មុំ | ទឹកប្រាក់ ៦.០០០ ដុល្លារ |

ឃ

**គ-មេជាយស៊ីរន្តស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ច្រាជ្ញ គង់** | សប្បុរសជននៅខេត្តកំពង់ចាម | ទឹកប្រាក់ ៤.៥០០ ដុល្លារ |
| ២-លោក | **សាយ ឃឹម** | សប្បុរសជននៅខេត្តកំពង់ចាម | ទឹកប្រាក់ ៣.៨៨៤ ដុល្លារ |
| ៣-លោក | **មាស សឿន** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល | ទឹកប្រាក់ ៣.៧០០ ដុល្លារ |
| ៤-លោក | **កែវ ញឿន** | សប្បុរសជននៅខេត្តកំពង់ចាម | ទឹកប្រាក់ ៣.១៥០ ដុល្លារ |
| ៥-លោក | **ឃាត់ ហ៊ីន** | សប្បុរសជននៅខេត្តកំពង់ចាម | ទឹកប្រាក់ ៣.១០០ ដុល្លារ |
| ៦-លោក | **ខឹម សារិន** | សប្បុរសជននៅខេត្តកំពង់ចាម | ទឹកប្រាក់ ៣.២៣០ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥៥...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៩រូប ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារ និង សមិទ្ធផលផ្សេងៗទៀត ក្នុងវត្តពោធិវង្សលើ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយព្រះនាម និង នាម ខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| -លោកយាយ | **ទិច ' ហុង** | នៅភ្នំពេញ | ថវិកា ចំនួន | ២០.០០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ឆាយ សុវណ្ណ** | នៅភ្នំពេញ | ថវិកា ចំនួន | ៦.៥០០ ដុល្លារ |
| ២-លោក | **ហេង សារ៉ាត់** | នៅភ្នំពេញ | ថវិកា ចំនួន | ៥.០០០ ដុល្លារ |

**គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សោ ហ៊ី** | នៅខេត្តតាកែវ | បច្ច័យ ចំនួន | ១.៥៣០ ដុល្លារ |
| ២-ព្រះតេជគុណ | **ស៊ី សុវណ្ណ** | នៅខេត្តតាកែវ | បច្ច័យ ចំនួន | ១.៣៥០ ដុល្លារ |
| ៣-លោក | **ឃុត ផន** | នៅខេត្តតាកែវ | ថវិកា ចំនួន | ១.០០០ ដុល្លារ |
| ៤-លោក | **តឹក ស៊ីម** | នៅភ្នំពេញ | ថវិកា ចំនួន | ១.០០០ ដុល្លារ |
| ៥-លោក | **គង់ ភ្នី** | នៅភ្នំពេញ | ថវិកា ចំនួន | ១.០០០ ដុល្លារ |
| ៦-លោក | **ចេង សាវី** | នៅខេត្តតាកែវ | ថវិកា ចំនួន | ១.០០០ ដុល្លារ |

W

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

118

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ . បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**មាត្រា ១** : ផ្ទេរភារកិច្ចលោក **នួច សុចន្ត្រី** បច្ចុប្បន្នអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា អោយមកបំរើការងារនៅអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ នៃក្រសួងពត៌មាន ។

**មាត្រា ២** : សេចក្តីសំរេចរបស់ក្រសួងពត៌មាន លេខ ០០៣៣/៩៩ ព.ម/បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការប្រគល់សិទ្ធិគ្រប់គ្រង ដឹកនាំ និងរៀបចំកិច្ចដំណើរការផ្សាយរបស់វិទ្យុ អេហ្វ អ៊ឹម ៩៦ ម៉េហ្គាហឺត នៃក្រសួងពត៌មាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៣*

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៥៦...អន/ក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ . បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១** : តែងតាំងលោក **គួច សារ៉េត** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានផលិតកម្មវិធី ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ទទួលបន្ទុកគ្រប់គ្រង ដឹកនាំ និងរៀបចំកិច្ចដំណើរការនៃស្ថានីយ៍វិទ្យុ អេហ្វ អ៊ឹម ជាតិកម្ពុជា ៩៦ មេហ្គាហ៊ឺត ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគ កំលាំង កាយ-ចិត្ត និង ធនធានយ៉ាងច្រើន សំរាប់ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យ អប់រំ សង្គមកិច្ច និង ព្រះពុទ្ធសាសនា នៅខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឯកឧត្តម | **ចំន្ទ សារុន** | រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| ២-ឯកឧត្តម | **សូរ ឃុន** | រដ្ឋមន្ត្រីក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៥៨...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ វត្តព្នៅ ស្ថិតនៅក្នុងឃុំព្នៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **យឹម ហ៊ាន់** | ព្រះចៅអធិការវត្តព្នៅ | បច្ច័យ ៣០.២១០ USD |
| ២-លោក | **ញ៉ឹក ទីវ៉ាត់** | នាយកក្រុមហ៊ុន នាគប្រាំពីរ | ថវិកា ១០៣.៧៧៩ USD |
| ៣-លោក | **ស ហ៊ឹម** | នាយកក្រុមហ៊ុន អៀង វ៉ាន | ថវិកា ៣៣.៧១៦ USD |
| ៤-លោក | **ឧ មូណារី** និង លោកស្រី **នន់ ស៊ីផារ៉ា** | | ថវិកា ២៧.០០០ USD |
| ៥-លោកស្រី | **អៀង ម៉ាន** | | ថវិកា ២៦.៣០០ USD |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ឯកឧត្តម **ម៉ុក ម៉ារ៉ែត** | និង លោកជំទាវ | ថវិកា | ៤៥.០០០.០០០ រៀល |
| | | និង | ១.៨៥០ USD |
| ២-ព្រះតេជគុណ **អ៊ិត អ៊ូ** | ចៅអធិការវត្តត្រពាំងធំខាងត្បូង | បច្ច័យ | ៤២៤..១៥៤.៨០០ រៀល |
| | | និង | ១៤៨.០៣៥ USD |
| ៣-លោក **ហ៊ូ សុគន្ធ** | តំណាងសប្បុរសជនខ្មែរនៅអាមេរិក | ថវិកា | ២៤.៩១៥ USD |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនកូរ៉េ ចំនួន ០២រូប ដែលបានជួយឧបត្ថម្ភដល់ការបណ្តុះបណ្តាលភាសាអង់គ្លេស ពតិមានវិទ្យា ដល់កងយោធពលខេមរភូមិន្ទរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១- Ph.D , LEE SANG CHUN , President of Yeungnam University

២- Mr LEE JEA SEUNG , Special Assistant the National Assembly of Republic of Korea

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោកវរសេនីយ៍ឯក **ហេង ឌុន្នី** នាយករងទីចាត់ការអភិវឌ្ឍន៍នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃល្អ ក្នុងការទំនាក់ទំនងស្វែងរកជំនួយ មកបំរើការងារអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច ✓

-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៦២ អនក្រ.បក - ៩៩

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/ ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់អភិបាលខេត្តតាកែវ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១១ រូប ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធិផលនានាដូចជា : កសាងព្រះវិហារ កុដិ ០២ខ្នង អាគារសិក្សា ០១ខ្នង ក្លោងទ្វារ និង របងវត្ត ស្ថិតនៅក្នុងវត្តសូភីឧត្ដម ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយ ព្រះនាម និង នាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១- ព្រះតេជគុណ **ឈុប ម៉ៃ** បច្ច័យ ២៧,៧១១ USD

២- ព្រះតេជគុណ **ម៉ុល នេត** បច្ច័យ ២០,១៥០ USD

៣- លោក ស្រី និ ថវិកា ១២,៩៥០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១- ឯកឧត្តម ហ៊ឹង ប៊ុនហៀង ថវិកា ៥,៥៧០ USD

២- លោក ម៉ក់ សារ៉េត ថវិកា ៥,១០០ USD

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១- ឯកឧត្តម ស៊ូ តិរិទ្ធ ថវិកា ១,៥៥០ USD

២- លោក គង់ ចាន់ ថវិកា ៣,៧៥០ USD

៣- លោក សុខ យិន ថវិកា ១,៤៨០ USD

៤- លោក នន ឈិន ថវិកា ១,៤៤៥ USD

៥- លោក អ៊ុន ខ្មៅ ថវិកា ១,២៥០ USD

៦- លោក ទេព ម៉ន ថវិកា ១,២២០ USD

៧- លោក មុំ ទ៉ាត ថវិកា ១,១៨០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៦៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **មាស ជម** សញ្ជាតិអាមេរិក ដែលបានជួយកសាងសាលារៀន ០១ខ្នង មាន ០៣ បន្ទប់ ជូនប្រជាពលរដ្ឋនៅភូមិស្វាយបូព្រៃក្បុ ឃុំជាខ្លាង ស្រុកព្រៃវែង និង គ្រែពេទ្យចំនួន ១០ សំរាប់ ជូនមណ្ឌលសុខភាព ស្ថិតនៅក្នុងខេត្តព្រៃវែង សរុបទឹកប្រាក់ចំនួន ១៣.៥០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនកញ្ញា **អ៊ឹម រតនា** សប្បុរសជននៅទីក្រុងឡុងប៊ិច សហរដ្ឋអាមេរិក ដែលបានចំណាយថវិកាជួយកសាងសមិទ្ធផលនានា ជូនប្រជាពលរដ្ឋក្រីក្រនៅតាមឃុំនានា ស្ថិតនៅក្នុងខេត្តកំពង់ធំ សរុបទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៦៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន ៩៧ រូប ដែលមានស្នាដៃក្នុងការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល លើវិស័យអាកាសចរស៊ីវិលទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ុន** | **រដ្ឋា** | នាយកអាកាសយានដ្ឋានសៀមរាប |
| ២-លោក | **គិត** | **សាលី** | អនុប្រធាននាយកដ្ឋាន |

**ខ-មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ហ៊ឹម** | **សារុន** | អនុប្រធាននាយកដ្ឋាន |
| ២-លោក | **ពុធ** | **សុខា** | អនុប្រធាននាយកដ្ឋាន |
| ៣-លោក | **ស៊ូ** | **កិត្យា** | អនុប្រធាននាយកដ្ឋាន |

**គ-មេដាយសំរិទ្ធការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **ឈុម** | **ចន្ទរិទ្ធ** | អនុប្រធានការិយាល័យ |
| ២-លោក | **សុខ** | **សាខន** | ប្រធានការិយាល័យ |
| ៣-លោក | **គីម** | **ឫទ្ធី** | អនុប្រធានការិយាល័យ |
| ៤-លោក | **សុខ** | **ស៊ីម៉ាណា** | ភ្នាក់ងាររដ្ឋបាល |

| | | |
|---|---|---|
| ៥-លោក | សារិន គុណ្ណាករ | អនុប្រធានការិយាល័យ |
| ៦-លោក | សុខ ថែម | អនុប្រធានការិយាល័យ |
| ៧-លោក | សំ សារឿន | អនុប្រធានការិយាល័យ |
| ៨-លោក | មឿន សាខន | ប្រធានការិយាល័យ |
| ៩-លោក | ឆាយ វណ្ណះ | ប្រធានការិយាល័យ |
| ១០-លោកស្រី | សុខ មុនី | លេខាធិការ |
| ១១-លោក | គង់ ពិដោរ | មន្ត្រីគ្រប់គ្រងរដ្ឋបាល |
| ១២-លោក | អោយ សុឃាង | មន្ត្រីក្រមការ |
| ១៣-លោក | ឡុង រដ្ឋា | អនុប្រធានការិយាល័យ |
| ១៤-លោក | តុល បូរិន | ប្រធានការិយាល័យ |
| ១៥-លោក | គីម ចាន់ណារិទ្ធ | អនុប្រធានការិយាល័យ |
| ១៦-លោក | ពៅ វុទ្ធី | អនុប្រធានការិយាល័យ |
| ១៧-កញ្ញា | អ៊ុំ ចាន់ធី | លេខាធិការ |
| ១៨-លោកស្រី | នូ នាដីកា | ប្រធានការិយាល័យ |
| ១៩-លោក | គង់ សុម៉ៅ | អនុប្រធានការិយាល័យ |
| ២០-លោក | ជា មករា | មន្ត្រីក្រមការ |
| ២១-លោក | ជៀវ វិន | អនុប្រធានការិយាល័យ |
| ២២-លោក | ឌី ហង្សា | អនុប្រធានការិយាល័យ |
| ២៣-លោក | អ៊ុក ចាន់ធា | មន្ត្រីគ្រប់គ្រងរដ្ឋបាល |
| ២៤-លោក | លី ឡុង | ប្រធានការិយាល័យ |
| ២៥-លោក | អ៊ិន ធីត្យ | អនុប្រធានការិយាល័យ |
| ២៦-លោក | ស្រី វណ្ណា | អនុប្រធានការិយាល័យ |
| ៦- | លោក ឈួន វេន | មេឃុំ ច្រាច់ | ស្រុកជ័យសែន |
| ៧- | លោក យូ រស់ | មេឃុំ ឆែបមួយ | ស្រុកឆែប |
| ៨- | លោក កែវ យិន | មេឃុំ ឆែបពីរ | ស្រុកឆែប |
| ៩- | លោក ទិត ផូ | មេឃុំ សង្កែមួយ | ស្រុកឆែប |
| ១០- | លោក ប៉ែន សួន | មេឃុំ សង្កែពីរ | ស្រុកឆែប |
| ១១- | លោក គឹម ពឿន | មេឃុំ មួព្រៃមួយ | ស្រុកឆែប |

| | | | |
|---|---|---|---|
| ១២- | លោក ញឿង ឡាយ | មេឃុំ ម្លូព្រៃពីរ | ស្រុកឆែប |
| ១៣- | លោក ប៊ុន ថុង | មេឃុំ កំពង់ស្រឡៅមួយ | ស្រុកឆែប |
| ១៤- | លោក នឹង ថុង | មេឃុំ កំពង់ស្រឡៅពីរ | ស្រុកឆែប |
| ១៥- | លោក ជៀម ជុន | មេឃុំ ទឹកក្រហម | ស្រុកជាំក្សាន្ត |
| ១៦- | លោក ទន់ សឿន | មេឃុំ កន្ទួត | ស្រុកជាំក្សាន្ត |
| ១៧- | លោក ហេង ផេន | មេឃុំ ព្រីងធំ | ស្រុកជាំក្សាន្ត |
| ១៨- | លោក ស៊ុន មួយ | មេឃុំ ជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ១៩- | លោក ពៅ វៃន | មេឃុំ រំដោះស្រែ | ស្រុកជាំក្សាន្ត |
| ២០- | លោក ដួង សាមឿន | មេឃុំ យាង | ស្រុកជាំក្សាន្ត |
| ២១- | លោក ចេង ជួន | មេឃុំ គូលែនជើង | ស្រុកគូលែន |
| ២២- | លោក ពេញ ថៃម | មេឃុំ ភ្នំពេញ | ស្រុកគូលែន |
| ២៣- | លោក អ៊ឹម ទិត | មេឃុំ ភ្នំត្បែងពីរ | ស្រុកគូលែន |
| ២៤- | លោកស្រី ប៉ែន ជាតិ | មេឃុំ ស្រយ៉ង់ | ស្រុកគូលែន |
| ២៥- | លោក បៀម ពេញ | មេឃុំ ថ្មី | ស្រុកគូលែន |
| ២៦- | លោក ស៊ឹម សែម | មេឃុំ គូលែនត្បូង | ស្រុកគូលែន |
| ២៧- | លោក សុខ ម៉ារុន | មេឃុំ របៀប | ស្រុករវៀង |
| ២៨- | លោក ថោង ឡុង | មេឃុំ រុងរឿង | ស្រុករវៀង |
| ២៩- | លោក ហេង ជ័យ | មេឃុំ រហ័ស | ស្រុករវៀង |
| ៣០- | លោក សុខ លុយ | មេឃុំ រស្មី | ស្រុករវៀង |
| ៣១- | លោក ជួន ជឿន | មេឃុំ រួសរាន់ | ស្រុករវៀង |
| ៣២- | លោក ចែត រួត | មេឃុំ រក្សា | ស្រុករវៀង |
| ៣៣- | លោក សោម ភារៈ | មេឃុំ រំដោះ | ស្រុករវៀង |
| ៣៤- | លោក លន់ ជា | មេឃុំ រមទម្យ | ស្រុករវៀង |
| ៣៥- | លោក សួរ សៀ | មេឃុំ រមណីយ៍ | ស្រុករវៀង |
| ៣៦- | លោក ដួង ឡុង | មេឃុំ រីករាយ | ស្រុករវៀង |
| ៣៧- | លោក ពៅ គឿន | មេឃុំ រតនៈ | ស្រុករវៀង |
| ៣៨- | លោក លិន ចាន់ហៀង | មេឃុំ រៀបរយ | ស្រុករវៀង |
| ៣៩- | លោក គង់ ឡេន | មេឃុំ ចំរើន | ស្រុកសង្គមថ្មី |
| ៤០- | លោក ឧង សុន | មេឃុំ ស្ពៅ | ស្រុកសង្គមថ្មី |
| ៤១- | លោក ក្រូច ឌុល | មេឃុំ រណសិរ្ស | ស្រុកសង្គមថ្មី |
| ៤២- | លោក អ៊ុំ ធួន | មេឃុំ ភ្នំត្បែងមួយ | ស្រុកសង្គមថ្មី |
| ៤៣- | លោក សុខ ខុន | មេឃុំ រអាង | ស្រុកសង្គមថ្មី |
| ៤៤- | លោក កុក ឈួន | មេឃុំ កំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ៤៥- | លោក យូ សំអឿន | មេឃុំ ប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ៤៦- | លោក វង់ កួយ | មេឃុំ ឈានមុខ | ស្រុកត្បែងមានជ័យ |

ឃ

| | | | |
|---|---|---|---|
| ៤៧- | លោក ប្រាក់ កែន | មេឃុំ ប្រមេរុ | ស្រុកត្បែងមានជ័យ |
| ៤៨- | លោក វង់ លត់ | មេឃុំ ព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ៤៩- | លោក សេង ឆាយ | មេឃុំ ពោធិ៍ | ស្រុកត្បែងមានជ័យ |

ខ-**មេដាយប្រាក់ការងារ** :

| | | | |
|---|---|---|---|
| ១- | លោក លាស់ នី | ជំទប់ទី១ ឃុំស្លែង | ស្រុកជ័យសែន |
| ២- | លោក ប្រែង អឿន | ជំទប់ទី២ ឃុំស្លែង | ស្រុកជ័យសែន |
| ៣- | លោក សុខ ឃីម | ជំទប់ទី៣ ឃុំស្លែង | ស្រុកជ័យសែន |
| ៤- | លោក ផៃ រ៉េម | ជំទប់ទី១ ឃុំពុទ្រា | ស្រុកជ័យសែន |
| ៥- | លោក ភោគ ធឿន | ជំទប់ទី២ ឃុំពុទ្រា | ស្រុកជ័យសែន |
| ៦- | លោក សៅ ធន | ជំទប់ទី៣ ឃុំពុទ្រា | ស្រុកជ័យសែន |
| ៧- | លោក យ៉ាន់ យ៉ន | ជំទប់ទី១ ឃុំតស៊ូ | ស្រុកជ័យសែន |
| ៨- | លោក រស់ អួន | ជំទប់ទី២ ឃុំតស៊ូ | ស្រុកជ័យសែន |
| ៩- | លោក ព្រំ សោន | ជំទប់ទី៣ ឃុំតស៊ូ | ស្រុកជ័យសែន |
| ១០- | លោក អៀម សារ៉ាត | ជំទប់ទី១ ឃុំខ្យង | ស្រុកជ័យសែន |
| ១១- | លោក មិន យឿង | ជំទប់ទី២ ឃុំខ្យង | ស្រុកជ័យសែន |
| ១២- | លោក ស្វាយ វ៉ុន | ជំទប់ទី៣ ឃុំខ្យង | ស្រុកជ័យសែន |
| ១៣- | លោក សោម អ៊ិត | ជំទប់ទី១ ឃុំផ្លារ | ស្រុកជ័យសែន |
| ១៤- | លោក យឹង ហុន | ជំទប់ទី២ ឃុំផ្លារ | ស្រុកជ័យសែន |
| ១៥- | លោក ខែន ដែន | ជំទប់ទី៣ ឃុំផ្លារ | ស្រុកជ័យសែន |
| ១៦- | លោក សៅ សំ | ជំទប់ទី១ ឃុំប្រាថ់ | ស្រុកជ័យសែន |
| ១៧- | លោក យូ ជុន | ជំទប់ទី២ ឃុំប្រាថ់ | ស្រុកជ័យសែន |
| ១៨- | លោក ម៉ាត់ ឡាញ់ | ជំទប់ទី៣ ឃុំប្រាថ់ | ស្រុកជ័យសែន |
| ១៩- | លោក ពៅ ស៊ិង | ជំទប់ទី១ ឃុំឆែបមួយ | ស្រុកឆែប |
| ២០- | លោក ទៀន ធៀក | ជំទប់ទី២ ឃុំឆែបមួយ | ស្រុកឆែប |
| ២១- | លោក មាស ផៃ | ជំទប់ទី៣ ឃុំឆែបមួយ | ស្រុកឆែប |
| ២២- | លោក ញូង សែម | ជំទប់ទី១ ឃុំឆែបពីរ | ស្រុកឆែប |
| ២៣- | លោក វឹម ចាន់ | ជំទប់ទី២ ឃុំឆែបពីរ | ស្រុកឆែប |
| ២៤- | លោក កែវ សុខឿន | ជំទប់ទី៣ ឃុំឆែបពីរ | ស្រុកឆែប |
| ២៥- | លោក រស់ សាមេត | ជំទប់ទី១ ឃុំសង្កែមួយ | ស្រុកឆែប |
| ២៦- | លោក យិន ម៉ាក់ | ជំទប់ទី២ ឃុំសង្កែមួយ | ស្រុកឆែប |
| ២៧- | លោក ព្រំ សុខ | ជំទប់ទី៣ ឃុំសង្កែមួយ | ស្រុកឆែប |
| ២៨- | លោក ម៉ា ឈួន | ជំទប់ទី១ ឃុំសង្កែពីរ | ស្រុកឆែប |
| ២៩- | លោក កែ ហាយ | ជំទប់ទី២ ឃុំសង្កែពីរ | ស្រុកឆែប |
| ៣០- | លោក គួច សាំ | ជំទប់ទី៣ ឃុំសង្កែពីរ | ស្រុកឆែប |
| ៣១- | លោក ម៉ុក គឹមហួរ | ជំទប់ទី១ ឃុំម្លូព្រៃមួយ | ស្រុកឆែប |

| | | | |
|---|---|---|---|
| ៣២- | លោក សួរ ប៊ុនធឿន | ជំទប់ទី២ ឃុំម្លូព្រៃមួយ | ស្រុកឆែប |
| ៣៣- | លោក ម៉ង់ ឈឿន | ជំទប់ទី៣ ឃុំម្លូព្រៃមួយ | ស្រុកឆែប |
| ៣៤- | លោក សូ កាន់ | ជំទប់ទី១ ឃុំម្លូព្រៃពីរ | ស្រុកឆែប |
| ៣៥- | លោក ផា លីម | ជំទប់ទី២ ឃុំម្លូព្រៃពីរ | ស្រុកឆែប |
| ៣៦- | លោក វីម ចែត្រ | ជំទប់ទី៣ ឃុំម្លូព្រៃពីរ | ស្រុកឆែប |
| ៣៧- | លោក វ៉ាន់ មុត | ជំទប់ទី១ ឃុំស្រឡៅមួយ | ស្រុកឆែប |
| ៣៨- | លោក ថោង អាន | ជំទប់ទី២ ឃុំស្រឡៅមួយ | ស្រុកឆែប |
| ៣៩- | លោក គង់ គីមនី | ជំទប់ទី៣ ឃុំស្រឡៅមួយ | ស្រុកឆែប |
| ៤០- | លោក ណាត សាឡុត | ជំទប់ទី១ ឃុំស្រឡៅពីរ | ស្រុកឆែប |
| ៤១- | លោក ឃួន ផាន់ | ជំទប់ទី២ ឃុំស្រឡៅពីរ | ស្រុកឆែប |
| ៤២- | លោក ឡុង ហេង | ជំទប់ទី៣ ឃុំស្រឡៅពីរ | ស្រុកឆែប |
| ៤៣- | លោក អ៊ិន សារិន | ជំទប់ទី១ ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៤៤- | លោក អ៊ិន ថុក | ជំទប់ទី២ ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៤៥- | លោក សុខ គាល់ | ជំទប់ទី៣ ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៤៦- | លោក តួច ធឿង | ជំទប់ទី១ ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៤៧- | លោក ស ម៉ាប់ | ជំទប់ទី២ ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៤៨- | លោក ឆែម សែង | ជំទប់ទី៣ ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៤៩- | លោក យាន់ កប | ជំទប់ទី១ ឃុំព្រីងធំ | ស្រុកជាំក្សាន្ត |
| ៥០- | លោក កេង វ៉ន | ជំទប់ទី២ ឃុំព្រីងធំ | ស្រុកជាំក្សាន្ត |
| ៥១- | លោក ទន់ ណាន | ជំទប់ទី៣ ឃុំព្រីងធំ | ស្រុកជាំក្សាន្ត |
| ៥២- | លោក ពៅ យឿន | ជំទប់ទី១ ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៥៣- | លោក សេត ធឿង | ជំទប់ទី២ ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៥៤- | លោក គង់ សឿង | ជំទប់ទី៣ ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៥៥- | លោក យិន ភួន | ជំទប់ទី១ ឃុំរំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៥៦- | លោក សូ ធឿន | ជំទប់ទី២ ឃុំរំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៥៧- | លោក ពៅ គីង | ជំទប់ទី៣ ឃុំរំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៥៨- | លោក ហ៊ីម ហឿន | ជំទប់ទី១ ឃុំយាង | ស្រុកជាំក្សាន្ត |
| ៥៩- | លោក សំ សុខេត | ជំទប់ទី២ ឃុំយាង | ស្រុកជាំក្សាន្ត |
| ៦០- | លោក ឈុត ណោន | ជំទប់ទី៣ ឃុំយាង | ស្រុកជាំក្សាន្ត |
| ៦១- | លោក ភីវ សៃ | ជំទប់ទី១ ឃុំគូលែនជើង | ស្រុកគូលែន |
| ៦២- | លោក មាស សារឿន | ជំទប់ទី២ ឃុំគូលែនជើង | ស្រុកគូលែន |
| ៦៣- | លោក វ៉ាន់ លន់ | ជំទប់ទី៣ ឃុំគូលែនជើង | ស្រុកគូលែន |
| ៦៤- | លោក កែ អុំ | ជំទប់ទី១ ឃុំភ្នំពេញ | ស្រុកគូលែន |
| ៦៥- | លោក ពិន ម៉ៅ | ជំទប់ទី២ ឃុំភ្នំពេញ | ស្រុកគូលែន |
| ៦៦- | លោក សូ យាប់ | ជំទប់ទី៣ ឃុំភ្នំពេញ | ស្រុកគូលែន |
| ៦៧- | លោក ភោគ ផាង | ជំទប់ទី១ ឃុំភ្នំត្បែងពីរ | ស្រុកគូលែន |

| | | | | |
|---|---|---|---|---|
| ៦៨- | លោក សៀង សាត | ជំទប់ទី២ | ឃុំភ្នំត្បែងពីរ | ស្រុកគូលែន |
| ៦៩- | លោក សៅ លួន | ជំទប់ទី៣ | ឃុំភ្នំត្បែងពីរ | ស្រុកគូលែន |
| ៧០- | លោក សាត់ ស៊ី | ជំទប់ទី១ | ឃុំស្រយ៉ង់ | ស្រុកគូលែន |
| ៧១- | លោក កុល ហាត | ជំទប់ទី២ | ឃុំស្រយ៉ង់ | ស្រុកគូលែន |
| ៧២- | លោក ប៉ែន ឡៃ | ជំទប់ទី៣ | ឃុំស្រយ៉ង់ | ស្រុកគូលែន |
| ៧៣- | លោក ណឹម សុខា | ជំទប់ទី១ | ឃុំថ្មី | ស្រុកគូលែន |
| ៧៤- | លោក ស៊ី ស្លួន | ជំទប់ទី២ | ឃុំថ្មី | ស្រុកគូលែន |
| ៧៥- | លោក គឹម អាន | ជំទប់ទី៣ | ឃុំថ្មី | ស្រុកគូលែន |
| ៧៦- | លោក ព្រីន ឃាត | ជំទប់ទី១ | ឃុំគូលែនត្បូង | ស្រុកគូលែន |
| ៧៧- | លោក សំ ផន | ជំទប់ទី២ | ឃុំគូលែនត្បូង | ស្រុកគូលែន |
| ៧៨- | លោក កែវ លឿង | ជំទប់ទី៣ | ឃុំគូលែនត្បូង | ស្រុកគូលែន |
| ៧៩- | លោក អៀម លន់ | ជំទប់ទី១ | ឃុំរបៀប | ស្រុករវៀង |
| ៨០- | លោក ថង សាន្តី | ជំទប់ទី២ | ឃុំរបៀប | ស្រុករវៀង |
| ៨១- | លោក ម៉ី ម៉ុន | ជំទប់ទី៣ | ឃុំរបៀប | ស្រុករវៀង |
| ៨២- | លោក ស៊ឹង សែនរិទ្ធី | ជំទប់ទី១ | ឃុំរុងរឿង | ស្រុករវៀង |
| ៨៣- | លោក តី សាង | ជំទប់ទី២ | ឃុំរុងរឿង | ស្រុករវៀង |
| ៨៤- | លោក គង់ គឹម | ជំទប់ទី៣ | ឃុំរុងរឿង | ស្រុករវៀង |
| ៨៥- | លោក ថោង ធុន | ជំទប់ទី១ | ឃុំរហ័ស | ស្រុករវៀង |
| ៨៦- | លោក គង់ សំអុន | ជំទប់ទី២ | ឃុំរហ័ស | ស្រុករវៀង |
| ៨៧- | លោក ហ៊ឹម ជួប | ជំទប់ទី៣ | ឃុំរហ័ស | ស្រុករវៀង |
| ៨៨- | លោក ស្រី ជឿន | ជំទប់ទី១ | ឃុំរស្មី | ស្រុករវៀង |
| ៨៩- | លោក ជំ ណំ | ជំទប់ទី២ | ឃុំរស្មី | ស្រុករវៀង |
| ៩០- | លោក ស្រី ជៀប | ជំទប់ទី៣ | ឃុំរស្មី | ស្រុករវៀង |
| ៩១- | លោក សួរ លី | ជំទប់ទី១ | ឃុំរួសរាន់ | ស្រុករវៀង |
| ៩២- | លោក ញាន ឡុំ | ជំទប់ទី២ | ឃុំរួសរាន់ | ស្រុករវៀង |
| ៩៣- | លោក គង់ តី | ជំទប់ទី៣ | ឃុំរួសរាន់ | ស្រុករវៀង |
| ៩៤- | លោក គឹម លួស | ជំទប់ទី១ | ឃុំរក្សា | ស្រុករវៀង |
| ៩៥- | លោក សួរ សារឿន | ជំទប់ទី២ | ឃុំរក្សា | ស្រុករវៀង |
| ៩៦- | លោក ទិត ស៊ីន | ជំទប់ទី៣ | ឃុំរក្សា | ស្រុករវៀង |
| ៩៧- | លោក សុខ នីន | ជំទប់ទី១ | ឃុំរំដោះ | ស្រុករវៀង |
| ៩៨- | លោក មាស សំអឿន | ជំទប់ទី២ | ឃុំរំដោះ | ស្រុករវៀង |
| ៩៩- | លោក ប៉េង លីផាត់ | ជំទប់ទី៣ | ឃុំរំដោះ | ស្រុករវៀង |
| ១០០- | លោក សុខ ខៀវ | ជំទប់ទី១ | ឃុំរមទម្យ | ស្រុករវៀង |
| ១០១- | លោក ជុំ ធី | ជំទប់ទី២ | ឃុំរមទម្យ | ស្រុករវៀង |
| ១០២- | លោក នួន ភារៈ | ជំទប់ទី៣ | ឃុំរមទម្យ | ស្រុករវៀង |
| ១០៣- | លោក សោម រ៉ុំ | ជំទប់ទី១ | ឃុំរម្មណីយ | ស្រុករវៀង |

| | | | |
|---|---|---|---|
| ១០៤- | លោក គៀត គៀន | ជំទប់ទី២ ឃុំរម្មណីយ | ស្រុករវៀង |
| ១០៥- | លោក គង់ ឡុង | ជំទប់ទី៣ ឃុំរម្មណីយ | ស្រុករវៀង |
| ១០៦- | លោក គឹម ព្រំ | ជំទប់ទី១ ឃុំរីករាយ | ស្រុករវៀង |
| ១០៧- | លោក សែន សឿន | ជំទប់ទី២ ឃុំរីករាយ | ស្រុករវៀង |
| ១០៨- | លោក ហេង ហឿ | ជំទប់ទី៣ ឃុំរីករាយ | ស្រុករវៀង |
| ១០៩- | លោក មាស ពោន | ជំទប់ទី១ ឃុំរតនៈ | ស្រុករវៀង |
| ១១០- | លោក ព្រំ លីម | ជំទប់ទី២ ឃុំរតនៈ | ស្រុករវៀង |
| ១១១- | លោក មាស ផន | ជំទប់ទី៣ ឃុំរតនៈ | ស្រុករវៀង |
| ១១២- | លោក មាស ណំ | ជំទប់ទី១ ឃុំរៀបរយ | ស្រុករវៀង |
| ១១៣- | លោក ឈុន មាស | ជំទប់ទី២ ឃុំរៀបរយ | ស្រុករវៀង |
| ១១៤- | លោក ប្រាក់ ឌុល | ជំទប់ទី៣ ឃុំរៀបរយ | ស្រុករវៀង |
| ១១៥- | លោក ស៊ឹង ស៊ីន | ជំទប់ទី១ ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១១៦- | លោក ជា ថែន | ជំទប់ទី២ ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១១៧- | លោក ហ៊ឹម ម៊ីម | ជំទប់ទី៣ ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១១៨- | លោក ឃុន ខេង | ជំទប់ទី១ ឃុំស្ដៅ | ស្រុកសង្គមថ្មី |
| ១១៩- | លោក កែវ តាំង | ជំទប់ទី២ ឃុំស្ដៅ | ស្រុកសង្គមថ្មី |
| ១២០- | លោក សុខ ជរ | ជំទប់ទី៣ ឃុំស្ដៅ | ស្រុកសង្គមថ្មី |
| ១២១- | លោក សេង សន | ជំទប់ទី១ ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១២២- | លោក ឈាន ឆាត់ | ជំទប់ទី២ ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១២៣- | លោក សោម ធី | ជំទប់ទី៣ ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១២៤- | លោក ស្រី សុត | ជំទប់ទី១ ឃុំភ្នំត្បែងមួយ | ស្រុកសង្គមថ្មី |
| ១២៥- | លោក សុង ស៊ុត | ជំទប់ទី២ ឃុំភ្នំត្បែងមួយ | ស្រុកសង្គមថ្មី |
| ១២៦- | លោក អ៊ូ រៀល | ជំទប់ទី៣ ឃុំភ្នំត្បែងមួយ | ស្រុកសង្គមថ្មី |
| ១២៧- | លោក សៀង អ៊ុល | ជំទប់ទី១ ឃុំរអាង | ស្រុកសង្គមថ្មី |
| ១២៨- | លោកស្រី ខៀវ វ៉ាន់ហួន | ជំទប់ទី២ ឃុំរអាង | ស្រុកសង្គមថ្មី |
| ១២៩- | លោក ញាន យាន | ជំទប់ទី៣ ឃុំរអាង | ស្រុកសង្គមថ្មី |
| ១៣០- | លោក សៀន សុធីវ័ត្ថ | ជំទប់ទី១ ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៣១- | លោក មាស រុន | ជំទប់ទី២ ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៣២- | លោក ហង់ ស៊ីម | ជំទប់ទី៣ ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៣៣- | លោក ប្រាក់ ហោ | ជំទប់ទី១ ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៣៤- | លោក ឆាត់ សុខជា | ជំទប់ទី២ ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៣៥- | លោក សាំង សឿង | ជំទប់ទី៣ ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៣៦- | លោក ខាត់ ប៊ុនធឿន | ជំទប់ទី១ ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ១៣៧- | លោក សេង អន | ជំទប់ទី២ ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ១៣៨- | លោក ភោគ ហួន | ជំទប់ទី៣ ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ១៣៩- | លោក លីម លេម | ជំទប់ទី១ ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |

| | | | |
|---|---|---|---|
| ១៤០- | លោក ហាយ ហាប់ | ជំទប់ទី២ ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |
| ១៤១- | លោក ជា ឈឿន | ជំទប់ទី៣ ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |
| ១៤២- | លោក បុណ្យ ធី | ជំទប់ទី១ ឃុំព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ១៤៣- | លោក ស្រី ឃឿន | ជំទប់ទី២ ឃុំព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ១៤៤- | លោក ឆុង ញាន | ជំទប់ទី៣ ឃុំព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ១៤៥- | លោក ឯក ឡាន់ | ជំទប់ទី១ ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ១៤៦- | លោក ហម បាន | ជំទប់ទី២ ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ១៤៧- | លោក ជុម ធឿន | ជំទប់ទី៣ ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |

**គ-មេភូមិខេត្តព្រះវិហារ :**

| | | | | |
|---|---|---|---|---|
| ១- | លោក ដួង សារវង្ស | មេភូមិ ស្លាង | ឃុំស្លាង | ស្រុកជ័យសែន |
| ២- | លោក ឈិន ធំ | មេភូមិ ទឹកលិច | ឃុំស្លាង | ស្រុកជ័យសែន |
| ៣- | លោក មាន ម៉ៅ | មេភូមិ គោក | ឃុំស្លាង | ស្រុកជ័យសែន |
| ៤- | លោក សួង សឹម | មេភូមិ ពើក | ឃុំពុទ្រា | ស្រុកជ័យសែន |
| ៥- | លោក ប្អូ លួន | មេភូមិ ពុទ្រា | ឃុំពុទ្រា | ស្រុកជ័យសែន |
| ៦- | លោក កែវ ឆែម | មេភូមិ បរ | ឃុំពុទ្រា | ស្រុកជ័យសែន |
| ៧- | លោក ទួន ខឹម | មេភូមិ ថ្មី | ឃុំតស៊ូ | ស្រុកជ័យសែន |
| ៨- | លោក ពុត លិន | មេភូមិ តស៊ូ | ឃុំតស៊ូ | ស្រុកជ័យសែន |
| ៩- | លោក ស្រី សោម | មេភូមិ សំរោង | ឃុំតស៊ូ | ស្រុកជ័យសែន |
| ១០- | លោក អៀម ប៊ីន | មេភូមិ ខ្យង | ឃុំខ្យង | ស្រុកជ័យសែន |
| ១១- | លោក ដួង សុផាត | មេភូមិ ស្នែង | ឃុំខ្យង | ស្រុកជ័យសែន |
| ១២- | លោក គីម ឈឿម | មេភូមិ ម៉ឺនរាជ្យ | ឃុំខ្យង | ស្រុកជ័យសែន |
| ១៣- | លោក សុខ ផុន | មេភូមិ ធ្នារ | ឃុំធ្នារ | ស្រុកជ័យសែន |
| ១៤- | លោក ថោង ឆាង | មេភូមិ ស្រែវាល | ឃុំធ្នារ | ស្រុកជ័យសែន |
| ១៥- | លោក គង់ ទៀង | មេភូមិ ភ្នាក់រលឹក | ឃុំធ្នារ | ស្រុកជ័យសែន |
| ១៦- | លោក មាស ឡាច | មេភូមិ បដិវត្ត | ឃុំប្រាច់ | ស្រុកជ័យសែន |
| ១៧- | លោក ផៃ ភី | មេភូមិ ផ្លោច | ឃុំប្រាច់ | ស្រុកជ័យសែន |
| ១៨- | លោក សុខ សាម | មេភូមិ ចំរើន | ឃុំប្រាច់ | ស្រុកជ័យសែន |
| ១៩- | លោក ផៃ វេង | មេភូមិ ប្រាច់ | ឃុំប្រាច់ | ស្រុកជ័យសែន |
| ២០- | លោក កែវ ភ័ក្រ | មេភូមិ ប្រមូលផ្តុំ | ឃុំប្រាច់ | ស្រុកជ័យសែន |
| ២១- | លោក ទិត បេន | មេភូមិ ដំណាក់ត្រាច | ឃុំប្រាច់ | ស្រុកជ័យសែន |
| ២២- | លោក ហ៊ុន ស៊ូ | មេភូមិ ឆែបកើត | ឃុំឆែបមួយ | ស្រុកឆែប |
| ២៣- | លោក ផាយ ភន | មេភូមិ ក្រសាំង | ឃុំឆែបមួយ | ស្រុកឆែប |
| ២៤- | លោក ញ៉ូវ តឿម | មេភូមិ ឆែបលិច | ឃុំឆែបមួយ | ស្រុកឆែប |
| ២៥- | លោក ផាវ ឈឿម | មេភូមិ ដងផ្លិត | ឃុំឆែបពីរ | ស្រុកឆែប |
| ២៦- | លោក ខឹម ផុន | មេភូមិ គុណភាពមួយ | ឃុំឆែបពីរ | ស្រុកឆែប |
| ២៧- | លោក ផាយ ស៊ុន | មេភូមិ គុណភាពពីរ | ឃុំឆែបពីរ | ស្រុកឆែប |

| | | | | | | |
|---|---|---|---|---|---|---|
| ២៨- | លោក | សារឿន | មេភូមិ | ណារុង | ឃុំឆែបពីរ | ស្រុកឆែប |
| ២៩- | លោក | មាស ឡាន់ | មេភូមិ | សង្កែ | ឃុំសង្កែមួយ | ស្រុកឆែប |
| ៣០- | លោក | ចាន់ លេន | មេភូមិ | សាអែម | ឃុំសង្កែមួយ | ស្រុកឆែប |
| ៣១- | លោក | ឈឹម ភេន | មេភូមិ | ជោគជ័យ | ឃុំសង្កែពីរ | ស្រុកឆែប |
| ៣២- | លោក | អ៊ុំ សំអុល | មេភូមិ | សំបួរ | ឃុំសង្កែពីរ | ស្រុកឆែប |
| ៣៣- | លោក | ចក ជីម | មេភូមិ | កាឡោត | ឃុំសង្កែពីរ | ស្រុកឆែប |
| ៣៤- | លោក | ព្រំ ខឿន | មេភូមិ | ម្លូព្រៃ | ឃុំម្លូព្រៃមួយ | ស្រុកឆែប |
| ៣៥- | លោក | អ៊ុំ សារិត | មេភូមិ | ក្តុល | ឃុំម្លូព្រៃមួយ | ស្រុកឆែប |
| ៣៦- | លោក | ញ៉ឹក ប៊ុនថុន | មេភូមិ | ពោធិ៍ទាប | ឃុំម្លូព្រៃមួយ | ស្រុកឆែប |
| ៣៧- | លោក | រួន ធឿ | មេភូមិ | បុស្ស | ឃុំម្លូព្រៃពីរ | ស្រុកឆែប |
| ៣៨- | លោក | រីម រឿន | មេភូមិ | ប្រើសក្អក | ឃុំម្លូព្រៃពីរ | ស្រុកឆែប |
| ៣៩- | លោក | កែវ ម៉ុន | មេភូមិ | កំពង់ស្រឡៅ | ឃុំកំពង់ស្រឡៅមួយ | ស្រុកឆែប |
| ៤០- | លោក | ឈាន់ លឿ | មេភូមិ | កំពង់ពោធិ៍ | ឃុំកំពង់ស្រឡៅមួយ | ស្រុកឆែប |
| ៤១- | លោក | ជួន ប៊ុន | មេភូមិ | ស្នួង | ឃុំកំពង់ស្រឡៅមួយ | ស្រុកឆែប |
| ៤២- | លោក | ជុយ ផាន់ | មេភូមិ | សង្កែ | ឃុំកំពង់ស្រឡៅមួយ | ស្រុកឆែប |
| ៤៣- | លោក | ជួន សាមីន | មេភូមិ | ខាំកើត | ឃុំកំពង់ស្រឡៅមួយ | ស្រុកឆែប |
| ៤៤- | លោក | សុត ស៊ីង | មេភូមិ | កំពង់ក្រសាំង | ឃុំកំពង់ស្រឡៅពីរ | ស្រុកឆែប |
| ៤៥- | លោក | ថង បៃ | មេភូមិ | កំពង់សាមី | ឃុំកំពង់ស្រឡៅពីរ | ស្រុកឆែប |
| ៤៦- | លោក | ម៉ម សាប់ | មេភូមិ | កំពង់ជ្រៃ | ឃុំកំពង់ស្រឡៅពីរ | ស្រុកឆែប |
| ៤៧- | លោក | សុខ ចាំ | មេភូមិ | កំពង់ព្រះឥន្ទ | ឃុំកំពង់ស្រឡៅពីរ | ស្រុកឆែប |
| ៤៨- | លោក | ម៉ម ជា | មេភូមិ | ទឹកក្រហម | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៤៩- | លោក | ស្វាយ សារិន | មេភូមិ | ចាត់តាំង | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៥០- | លោក | ទីត ឆន | មេភូមិ | ត្រពាំងធំ | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៥១- | លោក | ខុន សុខោន | មេភូមិ | សង្គមថ្មី | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៥២- | លោក | សៅ សារិ | មេភូមិ | អ្នកក្សាន្ត | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៥៣- | លោក | ឈួន ឈាង | មេភូមិ | របុញ | ឃុំទឹកក្រហម | ស្រុកជាំក្សាន្ត |
| ៥៤- | លោក | ឃិត សាមឿន | មេភូមិ | ចារ | ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៥៥- | លោក | គង់ ប្រុក | មេភូមិ | កន្ទួត | ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៥៦- | លោក | ទីង ណែម | មេភូមិ | អន្លង់វែង | ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៥៧- | លោក | ហាម យន | មេភូមិ | ស្រអែម | ឃុំកន្ទួត | ស្រុកជាំក្សាន្ត |
| ៥៨- | លោក | ឡឹក សំប៊ុន | មេភូមិ | ក្រឡាពាស | ឃុំព្រីងធំ | ស្រុកជាំក្សាន្ត |
| ៥៩- | លោក | អ៊ុយ បួន | មេភូមិ | ត្បាតពើយ | ឃុំព្រីងធំ | ស្រុកជាំក្សាន្ត |
| ៦០- | លោក | អេង ផេង | មេភូមិ | ជាំក្សាន្ត | ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៦១- | លោក | ហុក សូ | មេភូមិ | កោតស្រឡៅ | ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៦២- | លោក | ហៀប សុក | មេភូមិ | វាលធំ | ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៦៣- | លោក | ប៊ុន ណា | មេភូមិ | វាលពោធិ៍ | ឃុំជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ៦៤- | លោក | តូច កែវ | មេភូមិ | ស្រែ | ឃុំរំដោះស្រែ | ស្រុកជាំក្សាន្ត |

| | | | | |
|---|---|---|---|---|
| ៦៥- | លោក ប៊ុន សៀង | មេភូមិ ស្វាយ | ឃុំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៦៦- | លោក ឡេង យុត | មេភូមិ រលំថ្ម | ឃុំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៦៧- | លោក ចេក ប្រុក | មេភូមិ គោក | ឃុំដោះស្រែ | ស្រុកជាំក្សាន្ត |
| ៦៨- | លោក កាត់ សារុង | មេភូមិ យាង | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៦៩- | លោក ម៉ា សាមុត | មេភូមិ កោងយោង | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៧០- | លោក ប៊ូ យាម | មេភូមិ កំពេញ | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៧១- | លោក វ៉ែម សុផាន់ | មេភូមិ ជាំស្រែ | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៧២- | លោក ឆាត់ ឡាម | មេភូមិ រស្មី | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៧៣- | លោក ឯក យ៉ែម | មេភូមិ អន្ទិល | ឃុំយាង | ស្រុកជាំក្សាន្ត |
| ៧៤- | លោក សេត សាយ | មេភូមិ គូលែនជើង | ឃុំគូលេនជើង | ស្រុកគូលេន |
| ៧៥- | លោក ឃាន រំ | មេភូមិ ព្យជ្រូក | ឃុំគូលេនជើង | ស្រុកគូលេន |
| ៧៦- | លោក ចាន់ ឌី | មេភូមិ បុស្ស | ឃុំភ្នំពេញ | ស្រុកគូលេន |
| ៧៧- | លោក ថុន ថា | មេភូមិ ព្នៅ | ឃុំភ្នំពេញ | ស្រុកគូលេន |
| ៧៨- | លោក គង់ ដុំ | មេភូមិ ស្របាល | ឃុំភ្នំពេញ | ស្រុកគូលេន |
| ៧៩- | លោក ណម ផ្លូច | មេភូមិ បរិបូណ៌ | ឃុំភ្នំត្បែងពីរ | ស្រុកគូលេន |
| ៨០- | លោក ស៊ីវ សាខេង | មេភូមិ ឈូក | ឃុំភ្នំត្បែងពីរ | ស្រុកគូលេន |
| ៨១- | លោក ដែង ញឿរ | មេភូមិ ស្រឡៅ | ឃុំភ្នំត្បែងពីរ | ស្រុកគូលេន |
| ៨២- | លោក ឃួន សិន | មេភូមិ ក្ដាក់ | ឃុំភ្នំត្បែងពីរ | ស្រុកគូលេន |
| ៨៣- | លោក ភ្លួច ស្រប | មេភូមិ ស្រយ៉ង់ត្បូង | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៤- | លោក នៀប ម៉ឺន | មេភូមិ ស្រយ៉ង់ជើង | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៥- | លោក តុយ ប៉ែង | មេភូមិ កោះកេរ្តិ៍ | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៦- | លោក ថី ឆាង | មេភូមិ ម្រេច | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៧- | លោក នៀប ថាំង | មេភូមិ រំចេក | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៨- | លោក ចាន់ វេន | មេភូមិ សម្បូរ | ឃុំស្រយ៉ង់ | ស្រុកគូលេន |
| ៨៩- | លោក យ៉េន យឹម | មេភូមិ ថ្នល់បែក | ឃុំថ្មី | ស្រុកគូលេន |
| ៩០- | លោក ជា លោ | មេភូមិ ប្រកេវ | ឃុំថ្មី | ស្រុកគូលេន |
| ៩១- | លោក កម ជួប | មេភូមិ ពង្រ | ឃុំថ្មី | ស្រុកគូលេន |
| ៩២- | លោក សួស ជា | មេភូមិ ដំណាក់កន្ទួត | ឃុំថ្មី | ស្រុកគូលេន |
| ៩៣- | លោក សែន សៃ | មេភូមិ ដាន | ឃុំថ្មី | ស្រុកគូលេន |
| ៩៤- | លោក យឹម យ៉េង | មេភូមិ គូលេនត្បូង | ឃុំគូលេនត្បូង | ស្រុកគូលេន |
| ៩៥- | លោក ចាន់ ចេន | មេភូមិ ក្រពៅ | ឃុំគូលេនត្បូង | ស្រុកគូលេន |
| ៩៦- | លោក ម៉ឹក មាន | មេភូមិ ត្នោតម្លូ | ឃុំរបៀប | ស្រុករវៀង |
| ៩៧- | លោក ប្រាំង ហ៊ីង | មេភូមិ តាំងត្រក | ឃុំរបៀប | ស្រុករវៀង |
| ៩៨- | លោក គង់ ទីវ | មេភូមិ រវៀងជើង | ឃុំរបៀប | ស្រុករវៀង |
| ៩៩- | លោក សៅ សាន | មេភូមិ បាក់ក្ដោង | ឃុំរបៀប | ស្រុករវៀង |
| ១០០- | លោក ឈុន ឆៃ | មេភូមិ បឹង | ឃុំរបៀប | ស្រុករវៀង |
| ១០១- | លោក តី ភន | មេភូមិ អូរ | ឃុំរបៀប | ស្រុករវៀង |

| | | | | |
|---|---|---|---|---|
| ១០២- | លោក ប៉ាង គន | មេភូមិ រវៀងត្បូង | ឃុំរុងរឿង | ស្រុករវៀង |
| ១០៣- | លោក ឈុន ហ៊ុនលាង | មេភូមិ ថ្នល់កែង | ឃុំរុងរឿង | ស្រុករវៀង |
| ១០៤- | លោក ព្រំ ហេង | មេភូមិ បុស្សពៃ | ឃុំរុងរឿង | ស្រុករវៀង |
| ១០៥- | លោក ចាន់ ចន | មេភូមិ ស្រែធំ | ឃុំរុងរឿង | ស្រុករវៀង |
| ១០៦- | លោក ព្រំ រ៉ុម | មេភូមិ សង្កែរូង | ឃុំរហ័ស | ស្រុករវៀង |
| ១០៧- | លោក សុខ ហុន | មេភូមិ កក់ពោន | ឃុំរហ័ស | ស្រុករវៀង |
| ១០៨- | លោក ហឹម កេត | មេភូមិ កំពត | ឃុំរហ័ស | ស្រុករវៀង |
| ១០៩- | លោក យិន ភី | មេភូមិ ថ្កែង | ឃុំរហ័ស | ស្រុករវៀង |
| ១១០- | លោក ទឹក សាយ | មេភូមិ ចម្លង | ឃុំរហ័ស | ស្រុករវៀង |
| ១១១- | លោក សៅ ប៊ុង | មេភូមិ អន្លង់ស្វាយ | ឃុំរហ័ស | ស្រុករវៀង |
| ១១២- | លោក ព្រំ តែម | មេភូមិ តាតុង | ឃុំរស្មី | ស្រុករវៀង |
| ១១៣- | លោក ជុំ ហុន | មេភូមិ ដំណាក់ចិន | ឃុំរស្មី | ស្រុករវៀង |
| ១១៤- | លោក សួន សុន | មេភូមិ ចំបក់ផ្អែម | ឃុំរស្មី | ស្រុករវៀង |
| ១១៥- | លោក ថោង ប៊ុន | មេភូមិ ត្រពាំងឫស្សី | ឃុំរស្មី | ស្រុករវៀង |
| ១១៦- | លោក សុខ ភុំ | មេភូមិ ទម្លាប់ | ឃុំរួសរាន់ | ស្រុករវៀង |
| ១១៧- | លោក ទាន់ លី | មេភូមិ ឈ្នួន | ឃុំរួសរាន់ | ស្រុករវៀង |
| ១១៨- | លោក យិន ថោង | មេភូមិ ឫស្សីស្រុក | ឃុំរួសរាន់ | ស្រុករវៀង |
| ១១៩- | លោក តី យុន | មេភូមិ អន្លុងជ័យ | ឃុំរក្សា | ស្រុករវៀង |
| ១២០- | លោក ប៊ុន រី | មេភូមិ ពលកម្ម | ឃុំរក្សា | ស្រុករវៀង |
| ១២១- | លោក ស្រី វ៉ែត | មេភូមិ ស្រឡៅស្រោង | ឃុំរក្សា | ស្រុករវៀង |
| ១២២- | លោក យួន សាប់ | មេភូមិ ដូនម៉ា | ឃុំរក្សា | ស្រុករវៀង |
| ១២៣- | លោក សាក់ សាម | មេភូមិ សំរោង | ឃុំរក្សា | ស្រុករវៀង |
| ១២៤- | លោក សេក ខិត | មេភូមិ កក់ពោន | ឃុំរក្សា | ស្រុករវៀង |
| ១២៥- | លោក លាស់ ពៅ | មេភូមិ រំដោះ | ឃុំរក្សា | ស្រុករវៀង |
| ១២៦- | លោក សោម សំណាង | មេភូមិ ព្រាល | ឃុំរក្សា | ស្រុករវៀង |
| ១២៧- | លោក ស ព្រំ | មេភូមិ ឪឡឹក | ឃុំរំដោះ | ស្រុករវៀង |
| ១២៨- | លោក សោម ធឿន | មេភូមិ គោកអំពិល | ឃុំរំដោះ | ស្រុករវៀង |
| ១២៩- | លោក ឯម ផាត | មេភូមិ ថ្នល់កោង | ឃុំរំដោះ | ស្រុករវៀង |
| ១៣០- | លោក អោក ខឿន | មេភូមិ ស្វាយប៉ាត | ឃុំរំដោះ | ស្រុករវៀង |
| ១៣១- | លោក អ៊ុក គង់ | មេភូមិ ត្រពាំងទន្ទឹម | ឃុំរមទម្យ | ស្រុករវៀង |
| ១៣២- | លោក ស៊ូ ថា | មេភូមិ ទួលរវៀង | ឃុំរមទម្យ | ស្រុករវៀង |
| ១៣៣- | លោក សៅ ហ៊្សារ | មេភូមិ អូរតាឡុក | ឃុំរមទម្យ | ស្រុករវៀង |
| ១៣៤- | លោក សៀង ស៊ី | មេភូមិ បង្កើនផល | ឃុំរមទម្យ | ស្រុករវៀង |
| ១៣៥- | លោក ស៊ឹម យុត | មេភូមិ ស្វាយដំណាក់ថ្មី | ឃុំរមទម្យ | ស្រុករវៀង |
| ១៣៦- | លោក ឡូ រុន | មេភូមិ ស្វាយដំណាក់ចាស់ | ឃុំរមទម្យ | ស្រុករវៀង |
| ១៣៧- | លោក សេង ឈាង | មេភូមិ ភ្នំដែក | ឃុំរម្មណីយ | ស្រុករវៀង |
| ១៣៨- | លោក សោម កែ | មេភូមិ ស្រែឆ្នង់ | ឃុំរម្មណីយ | ស្រុករវៀង |

| | | | | |
|---|---|---|---|---|
| ១៣៩- | លោក ប៉ុន ភាព | មេភូមិ រំចេក | ឃុំរម្មណីយ | ស្រុករវៀង |
| ១៤០- | លោក ទេព ឆើត | មេភូមិ អូរពោធិ៍ | ឃុំរម្មណីយ | ស្រុករវៀង |
| ១៤១- | លោក អួន រឿន | មេភូមិ ជីអោក | ឃុំរម្មណីយ | ស្រុករវៀង |
| ១៤២- | លោក គង់ អឿន | មេភូមិ ដូង | ឃុំរីករាយ | ស្រុករវៀង |
| ១៤៣- | លោក សាត់ ហោន | មេភូមិ ចាំលហាល | ឃុំរីករាយ | ស្រុករវៀង |
| ១៤៤- | លោក ហ៊ា សំអួន | មេភូមិ បុស្ស | ឃុំរីករាយ | ស្រុករវៀង |
| ១៤៥- | លោក ដួង ហឿន | មេភូមិ កេរិ៍ | ឃុំតនះ | ស្រុករវៀង |
| ១៤៦- | លោក ខៀវ ហម | មេភូមិ សិរិត | ឃុំតនះ | ស្រុករវៀង |
| ១៤៧- | លោក ភោគ អាន | មេភូមិ ព្រៃស្នួល | ឃុំតនះ | ស្រុករវៀង |
| ១៤៨- | លោក ពុត តុ | មេភូមិ ខ្វា | ឃុំតនះ | ស្រុករវៀង |
| ១៤៩- | លោក មាស លួន | មេភូមិ សំព្រៀង | ឃុំតនះ | ស្រុករវៀង |
| ១៥០- | លោក សួ ថាត | មេភូមិ បង្កន | ឃុំរៀបរយ | ស្រុករវៀង |
| ១៥១- | លោក ចាប ជិន | មេភូមិ ស្រែ | ឃុំរៀបរយ | ស្រុករវៀង |
| ១៥២- | លោក ថុន ឈាន | មេភូមិ ខ្សែងទោល | ឃុំរៀបរយ | ស្រុករវៀង |
| ១៥៣- | លោក ស៊ឹង ហៀន | មេភូមិ ត្បែង | ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១៥៤- | លោក អ៊ី អាន | មេភូមិ ប្រធាតុ | ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១៥៥- | លោក ទាន់ ភៀង | មេភូមិ ដា | ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១៥៦- | លោក ស្រួម ឈួន | មេភូមិ ស្រីស្រណោះ | ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១៥៧- | លោក កើត ញ៉ើ | មេភូមិ សែនគង់ | ឃុំចំរើន | ស្រុកសង្គមថ្មី |
| ១៥៨- | លោក សៀង សឿន | មេភូមិ ស្ពៅ | ឃុំស្ពៅ | ស្រុកសង្គមថ្មី |
| ១៥៩- | លោក នូ សៀម | មេភូមិ សុច | ឃុំស្ពៅ | ស្រុកសង្គមថ្មី |
| ១៦០- | លោក ពៅ សាមុត | មេភូមិ តាបោះ | ឃុំស្ពៅ | ស្រុកសង្គមថ្មី |
| ១៦១- | លោក ព្រំ វន | មេភូមិ ត្រពាំងធ្លក | ឃុំស្ពៅ | ស្រុកសង្គមថ្មី |
| ១៦២- | លោក មាស រឿន | មេភូមិ ត្រពាំងខ្លែង | ឃុំស្ពៅ | ស្រុកសង្គមថ្មី |
| ១៦៣- | លោក លឹម សាង | មេភូមិ គោកថ្កូវ | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៤- | លោក មាស សិន | មេភូមិ ត្រពាំងរាំង | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៥- | លោក អ៊ុន លត់ | មេភូមិ តាសែងខាងជើង | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៦- | លោក គង់ នីម | មេភូមិ តាសែងកណ្ដាល | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៧- | លោក ភោគ គុណ | មេភូមិ ស្វាយ | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៨- | លោក អ៊ុន ធួន | មេភូមិ លំខ្សែង | ឃុំរណសិរ្ស | ស្រុកសង្គមថ្មី |
| ១៦៩- | លោក ឡា ម៉ៃ | មេភូមិ សំឡាញ | ឃុំក្តីត្បែងមួយ | ស្រុកសង្គមថ្មី |
| ១៧០- | លោក អ៊ូ សាវ៉ាន | មេភូមិ ក្បាលខ្លា | ឃុំក្តីត្បែងមួយ | ស្រុកសង្គមថ្មី |
| ១៧១- | លោក សាន់ ហ៊ុន | មេភូមិ អណ្ដូងភ្លូ | ឃុំអាង | ស្រុកសង្គមថ្មី |
| ១៧២- | លោក ឈុំ បត់ | មេភូមិ ក្តី | ឃុំអាង | ស្រុកសង្គមថ្មី |
| ១៧៣- | លោក ម៉ឹង ញិប | មេភូមិ បឹង | ឃុំអាង | ស្រុកសង្គមថ្មី |
| ១៧៤- | លោក ភ្លួច ភេន | មេភូមិ ខ្នុរ | ឃុំអាង | ស្រុកសង្គមថ្មី |
| ១៧៥- | លោក ប៉ឹក សែម | មេភូមិ ស្ទឹង | ឃុំអាង | ស្រុកសង្គមថ្មី |

| | | | | |
|---|---|---|---|---|
| ១៧៦- | លោក ហៀប សុក | មេភូមិ ខ្នារ | ឃុំអាង | ស្រុកសង្គមថ្មី |
| ១៧៧- | លោក សូ ប៊ុនកាន | មេភូមិ ថ្មី | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៧៨- | លោកស្រី យស់ វណ្ណដា | មេភូមិ ដំណាក់ | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៧៩- | លោកស្រី ពុត សាល | មេភូមិ ស្រះឈូក | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨០- | លោក ថៃ ហុង | មេភូមិ អណ្តូងពោធិ៍ | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨១- | លោក គង់ ស្នា | មេភូមិ គោកបេង | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨២- | លោក ប៉ែន គីមឃី | មេភូមិ ឡឥដ្ឋ | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨៣- | លោកស្រី ហេង វណ្ណនី | មេភូមិ កណ្តាល | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨៤- | លោក អៀង សារឿន | មេភូមិ សំរោង | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨៥- | លោក មាស ខឿន | មេភូមិ ទួលទំនប់ | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨៦- | លោក នៀម អ៊ំ | មេភូមិ កំពង់ចំលង | ឃុំកំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ១៨៧- | លោក អៀង ម៉ុក | មេភូមិ ចំការស្រមូវ | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៨៨- | លោក ទីម បូរ | មេភូមិ អភិវឌ្ឍន៍ | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៨៩- | លោក យៀង អ៊ី | មេភូមិ អូក្លែងព័រ | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩០- | លោក ទូច សាអ៊ីម | មេភូមិ ហ្សសែត | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩១- | លោក ផូង អុន | មេភូមិ ភារកិច្ច | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩២- | លោក ធិន ឃី | មេភូមិ ស្លាពរ | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩៣- | លោក ឈឹម ឃុន | មេភូមិ ឯកភាព | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩៤- | លោក សៅ លឹក | មេភូមិ ប៉ាលហាល | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩៥- | លោក ចៀម ម៉េង | មេភូមិ ទំនប់ | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩៦- | លោក គីម លី | មេភូមិ សាមគ្គី | ឃុំប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ១៩៧- | លោក ម៉ម ធី | មេភូមិ ចាក់កាំ | ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ១៩៨- | លោក សន ឃីម | មេភូមិ មហាផល | ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ១៩៩- | លោក ស៊ុំ បុន | មេភូមិ សេដ្ឋកិច្ច | ឃុំឈានមុខ | ស្រុកត្បែងមានជ័យ |
| ២០០- | លោក រដ្ឋ រឿន | មេភូមិ បុស្សធំ | ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |
| ២០១- | លោក ចាន់ ធី | មេភូមិ ស្រែព្រាង | ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |
| ២០២- | លោក សោម ប្រាក់ | មេភូមិ ប្រមេរុ | ឃុំប្រមេរុ | ស្រុកត្បែងមានជ័យ |
| ២០៣- | លោក បុណ្យ ឃួយ | មេភូមិ ក្រាំងដូង | ឃុំព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ២០៤- | លោក អ៊ុំ សាក់ | មេភូមិ អន្ទុងស្វាយ | ឃុំព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ២០៥- | លោក ឯក ចាន | មេភូមិ ពោធិ៍ | ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ២០៦- | លោក នៅ រក្សា | មេភូមិ ពោធិ៍ខឿន | ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ២០៧- | លោក ចុត ស្វាំង | មេភូមិ ស្រឡៅទូង | ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ២០៨- | លោក ទន់ ចំរើន | មេភូមិ អូរកក់ | ឃុំពោធិ៍ | ស្រុកត្បែងមានជ័យ |
| ២០៩- | លោក ជួន ឈឿន | ជំនួយការឃុំ ស្អាង | | ស្រុកជ័យសែន |
| ២១០- | លោក ស្រី ឡេង | ជំនួយការឃុំ ពុទ្រា | | ស្រុកជ័យសែន |
| ២១១- | លោក គង់ ធួន | ជំនួយការឃុំ តស៊ូ | | ស្រុកជ័យសែន |
| ២១២- | លោក ទីត សារុន | ជំនួយការឃុំ ខ្យង | | ស្រុកជ័យសែន |

| | | | |
|---|---|---|---|
| ២១៣- | លោក នង សែ | ជំនួយការឃុំ ឆ្អារ | ស្រុកជ័យសែន |
| ២១៤- | លោក ស្រី ថេន | ជំនួយការឃុំ ច្រាច់ | ស្រុកជ័យសែន |
| ២១៥- | លោក តេ សុឃន | ជំនួយការឃុំ ឆែបមួយ | ស្រុកឆែប |
| ២១៦- | លោក សួន សារ៉ាត | ជំនួយការឃុំ ឆែបពីរ | ស្រុកឆែប |
| ២១៧- | លោក ដាំ សួយ | ជំនួយការឃុំ សង្កែមួយ | ស្រុកឆែប |
| ២១៨- | លោក កែ ឈៀង | ជំនួយការឃុំ សង្កែពីរ | ស្រុកឆែប |
| ២១៩- | លោក វ៉ាង នៀង | ជំនួយការឃុំ ម្លូព្រៃមួយ | ស្រុកឆែប |
| ២២០- | លោក ប្រាក់ ប៉ាន់ | ជំនួយការឃុំ ម្លូព្រៃពីរ | ស្រុកឆែប |
| ២២១- | លោក ថ្វាង វ៉ា | ជំនួយការឃុំ កំពង់ស្រឡៅមួយ | ស្រុកឆែប |
| ២២២- | លោក ចិន្តា ថន | ជំនួយការឃុំ កំពង់ស្រឡៅពីរ | ស្រុកឆែប |
| ២២៣- | លោក មាស ទីម | ជំនួយការឃុំ ទឹកក្រហម | ស្រុកជាំក្សាន្ត |
| ២២៤- | លោក ស៊ុក ឈៀង | ជំនួយការឃុំ កន្ទួត | ស្រុកជាំក្សាន្ត |
| ២២៥- | លោក ឡាំ សោម | ជំនួយការឃុំ ព្រីងធំ | ស្រុកជាំក្សាន្ត |
| ២២៦- | លោក ញ៉ាក់ ភីម | ជំនួយការឃុំ ជាំក្សាន្ត | ស្រុកជាំក្សាន្ត |
| ២២៧- | លោក ថោង ហួន | ជំនួយការឃុំ រំដោះស្រែ | ស្រុកជាំក្សាន្ត |
| ២២៨- | លោក ពិន ងោ | ជំនួយការឃុំ យាង | ស្រុកជាំក្សាន្ត |
| ២២៩- | លោក បុណ្យ សំអឿន | ជំនួយការឃុំ គូលែនជើង | ស្រុកគូលែន |
| ២៣០- | លោក ជា ផៃ | ជំនួយការឃុំ ភ្នំពេញ | ស្រុកគូលែន |
| ២៣១- | លោក អិន សារិន | ជំនួយការឃុំ ភ្នំត្បែងពីរ | ស្រុកគូលែន |
| ២៣២- | លោក ហួន ចាន់ឿន | ជំនួយការឃុំ ស្រយ៉ង់ | ស្រុកគូលែន |
| ២៣៣- | លោក យ៉េន យិន | ជំនួយការឃុំ ថ្មី | ស្រុកគូលែន |
| ២៣៤- | លោក នង់ ឈួ | ជំនួយការឃុំ គូលែនត្បូង | ស្រុកគូលែន |
| ២៣៥- | លោក ង៉ែត សឿន | ជំនួយការឃុំ របៀប | ស្រុករវៀង |
| ២៣៦- | លោក នង សុខុម | ជំនួយការឃុំ រុងរឿង | ស្រុករវៀង |
| ២៣៧- | លោក ងួន វណ្ណេ | ជំនួយការឃុំ រហ័ស | ស្រុករវៀង |
| ២៣៨- | លោក សោម ឆេង | ជំនួយការឃុំ រស្មី | ស្រុករវៀង |
| ២៣៩- | លោក ដាំ យុត | ជំនួយការឃុំ រួសរាន់ | ស្រុករវៀង |
| ២៤០- | លោក ផែង គី | ជំនួយការឃុំ រក្សា | ស្រុករវៀង |
| ២៤១- | លោក តឹក មឹង | ជំនួយការឃុំ រំដោះ | ស្រុករវៀង |
| ២៤២- | លោក អ៊ុង ងាំ | ជំនួយការឃុំ រមទម្យ | ស្រុករវៀង |
| ២៤៣- | លោក ឃុត រី | ជំនួយការឃុំ រមណីយ៍ | ស្រុករវៀង |
| ២៤៤- | លោក សំ សឿន | ជំនួយការឃុំ រីករាយ | ស្រុករវៀង |
| ២៤៥- | លោក នុត វ៉ា | ជំនួយការឃុំ រតនៈ | ស្រុករវៀង |
| ២៤៦- | លោក ប៊ិន គីម | ជំនួយការឃុំ រៀបរយ | ស្រុករវៀង |
| ២៤៧- | លោក ហៀម រ៉ុម | ជំនួយការឃុំ ចំរើន | ស្រុកសង្គមថ្មី |
| ២៤៨- | លោក ឡុង ឆោម | ជំនួយការឃុំ ស្ដៅ | ស្រុកសង្គមថ្មី |
| ២៤៩- | លោក ឡឹម ឡេន | ជំនួយការឃុំ រណសិរ្ស | ស្រុកសង្គមថ្មី |

| | | | |
|---|---|---|---|
| ២៥០- | លោក បិន ភា | ជំនួយការឃុំ ភ្នំត្បែងមួយ | ស្រុកសង្គមថ្មី |
| ២៥១- | លោក សុខ ខោន | ជំនួយការឃុំ រអាង | ស្រុកសង្គមថ្មី |
| ២៥២- | លោក ហៀង គីមហឿន | ជំនួយការឃុំ កំពង់ប្រណាក | ស្រុកត្បែងមានជ័យ |
| ២៥៣- | លោក ទិត ភក្តី | ជំនួយការឃុំ ប៉ាលហាល | ស្រុកត្បែងមានជ័យ |
| ២៥៤- | លោក រស់ សារី | ជំនួយការឃុំ ឈានមុខ | ស្រុកត្បែងមានជ័យ |
| ២៥៥- | លោក នួន លឿន | ជំនួយការឃុំ ប្រមេរុ | ស្រុកត្បែងមានជ័យ |
| ២៥៦- | លោក វ៉ាំង ភេន | ជំនួយការឃុំ ព្រះឃ្លាំង | ស្រុកត្បែងមានជ័យ |
| ២៥៧- | លោក ហ៊ិន រ៉ុំ | ជំនួយការឃុំ ពោធិ៍ | ស្រុកត្បែងមានជ័យ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្ត អនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ..៤៩...គស.សរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តក្រចេះ

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការ ការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត ប្រចាំនៅខេត្តក្រចេះ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឡូយ សុផាត** | អភិបាលខេត្ត | **ប្រធាន** |
| ២-ឯកឧត្តម | **ទ័ន ឈុនលី** | អភិបាលរងទី ១ ខេត្ត | **អនុប្រធាន** |
| ៣-លោកវរៈសេនីយ៍ឯក | **សូ នាក់** | ស្នងការនគរបាលខេត្ត | **សមាជិក** |
| ៤-លោកវរៈសេនីយ៍ឯក | **យឹម យាន** | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | **សមាជិក** |
| ៥-លោកវរៈសេនីយ៍ឯក | **សេក នី** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | **សមាជិក** |
| ៦-លោកវរៈសេនីយ៍ទោ | **ជួន ស៊ាងហាក់** | ស្នងការរងទី ១ នគរបាលខេត្ត | **សមាជិក** |
| ៧-លោក | **ចិន ហុងស្រ៊ី** | នាយរងទី១ ខុទ្ទកាល័យសាលាខេត្ត | **សមាជិក** |
| ៨-លោក | **នួច ហឿន** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | **សមាជិក** |
| ៩-លោក | **ជាម សារឹម** | ប្រធានមន្ទីរសុខាភិបាលខេត្ត | **សមាជិក** |
| ១០-លោក | **ឡាយ សុមេធី** | ប្រធានមន្ទីរប្រៃសណីយ៍ខេត្តខេត្ត | **សមាជិក** |
| ១១-លោក | **អ៊ុំ និត** | ប្រធានមន្ទីរសាធារណៈការខេត្ត | **សមាជិក** |

**ប្រការ២** : ការិយាល័យសន្តិសុខថ្នាក់ខេត្តមានភារកិច្ចៈ

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ តាមសេចក្តីសំរេចលេខ ០១សណរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមានស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំពត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម ឬកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧប្បទ្ទវហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលក្រចេះ ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយលើមូលដ្ឋាននៃគំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និងកងកម្លាំងទាំងអស់ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៩ សសរ

# សេចក្ដីសំរេច

## ស្ដីពីការផ្ទេរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ៍វិទ្យុ អេហ្វ អ៊ឹមជាតិកម្ពុជា ៩៦ មេហ្គាហឺត

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១៩៦ / ១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពតិមាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ . បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពតិមាន
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១** : ផ្ទេរចនាសម្ព័ន្ធគ្រប់គ្រងស្ថានីយ៍វិទ្យុអេហ្វ អ៊ឹមជាតិកម្ពុជា ៩៦ មេហ្គាហឺត បច្ចុប្បន្នស្ថិតក្រោមឱវាទផ្ទាល់ជាបណ្ដោះអាសន្នរបស់ទីស្ដីការក្រសួងពតិមាន អោយមកស្ថិតក្រោមឱវាទផ្ទាល់របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពតិមានវិញ ។

**ប្រការ ២** : សេចក្ដីសំរេចរបស់ក្រសួងពតិមាន លេខ ០០៧៨-៩៩ ព.ម ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតនាយកដ្ឋានវិទ្យុអេហ្វអ៊ឹមជាតិកម្ពុជា នៃក្រសួងពតិមាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពតិមាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..៥០..សសរ

# សេចក្តីសំរេច
## ស្តីពី
## ការកែសម្រួលសមាសភាពការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅក្រុងព្រះសីហនុ

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣

-យោងសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅក្រុងព្រះសីហនុ ។

-យោងតាមលិខិតលេខ ០៥៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាក្រុងព្រះសីហនុ

## សំរេច

**ប្រការ១** : ត្រូវបានកែសម្រួល តែងតាំងប្រធាន និងអនុប្រធានការិយាល័យសន្តិសុខថ្នាក់ក្រុង ប្រចាំនៅក្រុងព្រះសីហនុ មានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឈុន ស៊ីរុន** | អភិបាលរងទី ១ ក្រុង | **ប្រធាន** |
| ២-ឯកឧត្តម | **ប្រាក់ ស៊ីហារ៉ា** | អភិបាលរងទី ២ ក្រុង | **អនុប្រធាន** |

**<u>ប្រការ ២</u>** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួង-ការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការ-ដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថ-លើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

<u>កន្លែងទទួល:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល

-ដូចប្រការ២

-សាលាក្រុងព្រះសីហនុ

-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៩. សរណន

# សារាចរណែនាំ

## សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យ ទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា មានពិធីបុណ្យជាច្រើនប្រចាំឆ្នាំ ដូចជាព្រះរាជពិធីបុណ្យទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិនិងបុណ្យអន្តរជាតិ ។ បុណ្យទាំងនោះ ត្រូវប្រព្រឹត្តទៅជាទៀងទាត់តាមប្រតិទិនចន្ទគតិខ្លះ និងតាមសុរិយគតិខ្លះ។ ព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្មែរ តែងប្រារព្ធពិធីបុណ្យទាំងនោះ ជារៀងរាល់ឆ្នាំ ដោយរក្សាបាននូវខ្លឹមសារ និងរូបភាពចាត់តាំង ទៅតាមអត្ថន័យនៃបុណ្យនិមួយៗ ។

កន្លងមក ដើម្បីថែរក្សាការពារនូវប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វប្បធម៌ អរិយធម៌ ដែលជាអត្តសញ្ញាណដ៏ថ្លៃថ្នូរបស់ជាតិឱ្យបានគង់វង្ស រាជរដ្ឋាភិបាល តែងដាក់ចេញនូវសារាចរណែនាំ ដោយឡែកៗ ទៅតាមផ្នែកជំនាញនៃបុណ្យនិមួយៗ សម្រាប់រៀបចំចាត់តាំងអនុវត្ត នៃពិធីបុណ្យទាំងនោះ ទទួលបានលទ្ធផលល្អប្រសើរ ។

ក្នុងស្មារតីកែទម្រង់អត្ថបទបទដ្ឋាននៃការរៀបចំពិធីបុណ្យទាំងនោះ ឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាល ដាក់ចេញនូវសារាចរណែនាំរួមមួយ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ តាមកាលបរិច្ឆេទ និងខ្លឹមសារដូចខាងក្រោមនេះ :

### I. កាលបរិច្ឆេទ :

**ក/. ព្រះរាជពិធីបុណ្យទានសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា :**

- បុណ្យមាឃបូជា : ថ្ងៃ ១៥ កើត ខែ មាឃ
- បុណ្យវិសាខបូជា : ថ្ងៃ ១៥ កើត ខែ ពិសាខ
- បុណ្យច្រត់ព្រះនង្គ័ល : ថ្ងៃ ១-២-៣ និងថ្ងៃ ៤ រោច ខែ ពិសាខ
- បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ : ថ្ងៃ ១៤-១៥ រោច ខែ ភទ្របទ និង ១ កើត ខែ អស្សុជ
- បុណ្យកឋិនទាន : ពីថ្ងៃ ១ រោច ខែ អស្សុជ ដល់ ១៥ កើត ខែ កត្តិក
- បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក : ថ្ងៃ ១៤-១៥ កើត និង ថ្ងៃ ១ រោច ខែ កត្តិក
- បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ : ថ្ងៃទី ១៤-១៥-១៦ ខែ មេសា

**ខ/. ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ :**

- បុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** : ថ្ងៃទី ១៨ ខែ មិថុនា
- បុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** : ថ្ងៃទី ៣០-៣១ ខែ តុលា និង ថ្ងៃទី ០១ ខែ វិច្ឆិកា

គ/. **បុណ្យជាតិ** :

- បុណ្យប្រកាសរដ្ឋធម្មនុញ្ញ និង ព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះមហាក្សត្រ : ថ្ងៃទី ២៤ ខែ កញ្ញា
- បុណ្យឯករាជជាតិ : ថ្ងៃទី ០៩ ខែ វិច្ឆិកា

ឃ/. **ទិវាបុណ្យជាតិ** :

- បុណ្យជ័យជំនះលើរបបប្រល័យពូជសាសន៍ : ថ្ងៃទី ០៧ ខែ មករា
- ទិវាកំចាត់មីន : ថ្ងៃទី ២៤ ខែ កុម្ភៈ
- ទិវានយោបាយទឹក : ថ្ងៃទី ០៤ ខែ មីនា
- ទិវាកំចាត់រោគរបេង : ថ្ងៃទី ២៤ ខែ មីនា
- ទិវាវប្បធម៌ : ថ្ងៃទី ០៣ ខែ មេសា
- ទិវាសេរីភាពខាងពត៌មាន : ថ្ងៃទី ០៣ ខែ ឧសភា
- រុក្ខទិវា : ថ្ងៃទី ០៩ ខែ កក្កដា
- ទិវាទេសចរណ៍ : ថ្ងៃទី ២៧ ខែ កញ្ញា
- ទិវាមនុស្សចាស់ : ថ្ងៃទី ០១ ខែ តុលា
- ទិវាគ្រូបង្រៀន : ថ្ងៃទី ០៥ ខែ តុលា
- ទិវាសន្ធិសញ្ញាសន្តិភាពកម្ពុជានៅប៉ារីស : ថ្ងៃទី ២៣ ខែ តុលា

ង/. **ទិវាបុណ្យអន្តរជាតិ** :

- បុណ្យចូលឆ្នាំសកល : ថ្ងៃទី ០១ ខែ មករា
- ទិវានារីអន្តរជាតិ : ថ្ងៃទី ០៨ ខែ មីនា
- ទិវាពិភពលោកទឹកនិងឧតុនិយម : ថ្ងៃទី ២២ ខែ មីនា
- ទិវាសុខភាពពិភពលោក : ថ្ងៃទី ០៧ ខែ មេសា
- ទិវាពលកម្មអន្តរជាតិ : ថ្ងៃទី ០១ ខែ ឧសភា
- ទិវាកាកបាទក្រហមកម្ពុជា : ថ្ងៃទី ០៨ ខែ ឧសភា
- ទិវាកុមារអន្តរជាតិ : ថ្ងៃទី ០១ ខែ មិថុនា
- ទិវាបរិស្ថានអន្តរជាតិ : ថ្ងៃទី ០៥ ខែ មិថុនា
- ទិវាប្រឆាំងគ្រឿងញៀន : ថ្ងៃទី ២៦ ខែ មិថុនា
- ទិវាអនក្ខរកម្មអន្តរជាតិ : ថ្ងៃទី ០៨ ខែ កញ្ញា
- ទិវាសន្តិភាពអន្តរជាតិ : ថ្ងៃទី ២១ ខែ កញ្ញា
- ទិវាអនាម័យបរិស្ថាន : ថ្ងៃទី ២៣ ខែ វិច្ឆិកា
- ទិវាប្រឆាំងជម្ងឺអេដស៍ : ថ្ងៃទី ០១ ខែ ធ្នូ
- ទិវាសិទ្ធិមនុស្ស : ថ្ងៃទី ១០ ខែ ធ្នូ

## II. **ភារកិច្ចត្រូវអនុវត្ត** :

- ប្រគល់ភារកិច្ច ជូនក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាសប្រចាំឆ្នាំ នៅក្នុងព្រះបរមរាជវាំង ឱ្យស្របតាមប្រពៃណីជាតិ ប្រពៃណីសាសនា និងតាមការសព្វព្រះរាជហឫទ័យ របស់**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ .

- ប្រគល់ភារកិច្ចជូន គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងព្រះបរមរាជវាំង និងក្រសួងពាក់ព័ន្ធ ចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យជាតិ បុណ្យប្រពៃណីជាតិ បុណ្យប្រពៃណីសាសនា ឱ្យធានាបានរូបភាពចាត់តាំងនិងខ្លឹមសារ ស្របតាមគោលបំណង សំណូមពរ និងប្រធានបទ នៃបុណ្យ និមួយៗ ដោយត្រូវមានផែនការណែនាំលំអិត សម្រាប់អនុវត្តជាក់ស្តែង .

- ប្រគល់ភារកិច្ចជូនក្រសួង និងអង្គភាពសាមី ដែលជាសមាជិកគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដែលមានពាក់ព័ន្ធនឹងទិវាបុណ្យជាតិ-អន្តរជាតិ តាមផ្នែកជំនាញនិមួយៗ សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រៀបចំផែនការណែនាំលំអិត ស្តីពីអត្ថន័យខ្លឹមសារ រូបភាពចាត់តាំង គោលបំណង សំណូមពរ និងប្រធានបទ សម្រាប់ចាត់តាំងអនុវត្តឱ្យបានស្របទៅតាមសភាពការណ៍ប្រទេសជាតិ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល តាមដំណាក់កាលនិមួយៗ .

- ក្រសួងជំនាញនិមួយៗ ដែលពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងឬអង្គភាពសាមី បង្កលក្ខណៈងាយស្រួលតាមសមត្ថកិច្ច បំរើឱ្យការរៀបចំពិធីបុណ្យនិមួយៗ តាមសំណូមពរនិងតម្រូវការចាំបាច់នៃការចាត់តាំងរៀបចំ ឱ្យទទួលបានលទ្ធផលល្អ .

- ប្រគល់ភារកិច្ចជូនគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ធ្វើការណែនាំប្រជុំកំណត់បែងចែកភារកិច្ច ទៅគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន ឱ្យចាត់តាំងរៀបចំពិធីបុណ្យតាមប្រតិទិនកំណត់ ដោយផ្អែកលើខ្លឹមសារនិងរូបភាពចាត់តាំង ជាក់ស្តែង ។

## III. **មូលដ្ឋាន សម្ភារៈ ថវិកា :**

- ពាក់ព័ន្ធនឹងសម្ភារៈ ថវិកា ដែលត្រូវប្រើប្រាស់ និងចំណាយបំរើការរៀបចំពិធីបុណ្យនិមួយៗ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នសាមី ត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាពនូវថវិកាដែលមានក្នុងគម្រោងប្រចាំឆ្នាំរបស់ខ្លួន ដោយត្រូវថែ្ទប្រឹតនិងសន្សំសំចៃកម្រិតខ្ពស់ តែត្រូវធានាការរៀបចំឱ្យបានទទួលលទ្ធផលល្អប្រសើរ ។

- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈរៀបចំដោះស្រាយសម្ភារៈ ថវិកា និងត្រួតពិនិត្យម៉ត់ចត់នូវគម្រោងចំណាយបំរើការរៀបចំបុណ្យនិមួយៗ ដែលសាមីអង្គភាព បានលើកឡើង ។

ក្នុងករណី មានការចាត់តាំងរៀបចំបុណ្យជាលក្ខណៈពិសេស រាជរដ្ឋាភិបាល នឹងដាក់ចេញនូវសារាចរណែនាំមួយ ដោយឡែកសម្រាប់អនុវត្តជាក់ស្តែង ។

ក្រោយការប្រារព្ធពិធីបុណ្យនិមួយៗចប់សព្វគ្រប់ , សាមីក្រសួង ស្ថាប័ន ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ដើម្បីបូកសរុបរាយការណ៍ ជូនរាជរដ្ឋាភិបាល ។

ទទួលបានសារាចរណែនាំនេះ, រាជរដ្ឋាភិបាល សង្ឃឹមថា សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្ត-ក្រុង នឹងចាត់តាំងអនុវត្តទទួលបានលទ្ធផលល្អប្រសើរ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- អគ្គលេខាធិការដ្ឋាន គ.ប.ជ.អ
- ឯកសារ-កាលប្បវត្តិ

4

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៧២ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

★ ★ ★ ★

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២០២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការតែងតាំង ឯកឧត្តម ឃុន ជិនកេន ជាអគ្គលេខាធិការរង រាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- យោងតាមសេចក្តីត្រូវការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ១.-** ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម **ឃុន ជិនកេន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល អោយទទួលបន្ទុក ការងាររដ្ឋបាល បុគ្គលិក និងពិធីការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ២.-** ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល លោកប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានពិធីការ នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ ០៦ ឆ្នាំ២០០៣

**ទេសរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចប្រការ២
-ឯកសារ-កាលប្បវត្តិ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ទូរសារ : ០២៣ ៨៨០ ៦២៤ ទូរស័ព្ទ : ០១២ ៨៨១ ៩៦៦ . ០១២ ៨០៤ ៤៤២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

No ៤៨៧ ឧសថ - បស - ប្រក -

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

## របស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

*****

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ទៅជា នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ពិនិត្យសំណូមពរចាំបាច់របស់ក្រសួង

